រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# សេចក្តីណែនាំបច្ចេកទេស

# ស្តីពី

# ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

ខែមីនា ឆ្នាំ ២០១៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង ផែនការ**

លេខ : ០៧៤ ផក.

**ក្រសួងមហាផ្ទៃ**

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា១២ នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- យោងតាមស្មារតីកិច្ចប្រជុំលើកទី១៣របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កាលពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧។

## សម្រេច

**ប្រការ ១.-**

ដាក់ឲ្យប្រើប្រាស់ **"សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ"**។

**ប្រការ ២.-**

ក្រុមប្រឹក្សាឃុំ មេឃុំ និងគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ ត្រូវរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ស្របតាមសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំឲ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ដោយមានការយកចិត្តទុកដាក់លើបញ្ហាបរិយាប័ន្ន សមធម៌សង្គម និងការប្រែប្រួលអាកាសធាតុ។

**ប្រការ ៣.-**

ក្រសួងផែនការ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់ការអភិវឌ្ឍសមត្ថភាព និងការគាំទ្រដល់រដ្ឋបាលឃុំ ដើម្បីឲ្យរដ្ឋបាលឃុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសនេះ សម្រាប់ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

ក្រសួងផែនការ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមប្រឹក្សាឃុំ មេឃុំ ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **ទេសរដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រីក្រសួងផែនការ** |
| **សម្តេចក្រឡាហោម ស ខេង** | **ឆាយ ថន** |

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

# មាតិកា

## ផ្នែកទី១
## និដ្ឋភាពទូទៅ
## នៃការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ


១. អត្ថន័យនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល ១
២. គោលការណ៍ ១
៣. យន្តការ និងភារកិច្ច ១


## ផ្នែកទី២
## ទម្រង់សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ


១. ក្របមុខ ៤
២. មាតិកាសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ៥
៣. សេចក្ដីពន្យល់អំពីបណ្ដាសមាសធាតុនៃសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ៦


## ផ្នែកទី៣
## វិធីសាស្រ្តរៀបចំ និង
## កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ


ជំហានទី១ ៖ ការប្រមូលព័ត៌មានស្ដីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ១៤
ជំហានទី២ ៖ ការរៀបចំសេចក្ដីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ១៧
ជំហានទី៣ ៖ ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ២៣


## ផ្នែកទី៤
## ឧបសម្ព័ន្ធជាសម្រាប់ជំនួយស្មារតី
## នៅពេលរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ


ឧបសម្ព័ន្ធទី១ ៖ វិធីសាស្រ្តចាត់អាទិភាព ២៥
ឧបសម្ព័ន្ធទី២ ៖ វិធីសាស្រ្តវិភាគស្ថានភាព ២៦
ឧបសម្ព័ន្ធទី៣ ៖ សំណួរគន្លឹះសម្រាប់ក្រុមប្រឹក្សាពិនិត្យ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល ២៧
ឧបសម្ព័ន្ធទី៤ ៖ ការប្រជុំផ្សព្វផ្សាយ ២៨
ឧបសម្ព័ន្ធទី៥ ៖ ឧបករណ៍វិភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ៣០
ឧបសម្ព័ន្ធទី៦ ៖ ជំនួយស្មារតីសម្រាប់ការសរសេរស្ថានភាពទូទៅ ៣៧

# ផ្នែកទី១

# ទិដ្ឋភាពទូទៅនៃ

# ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

# និទ្ទេសភាពទូទៅ
# នៃការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

## ១. អត្ថន័យនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ គឺជាការធ្វើឱ្យខ្លឹមសារនៃផែនការអភិវឌ្ឍន៍ឃុំទៅជាសកម្មភាព ឬសេវាជាក់ស្ដែងដោយមានភ្ជាប់នូវចំណាយមូលនិធិ សំដៅលើកកម្ពស់ការផ្ដល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍនៅក្នុងឃុំសម្រាប់រយៈពេលបីឆ្នាំ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

ការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ឆ្លុះបញ្ចាំងពីគម្រោង ឬសេវាជាអាទិភាព និងតម្លៃតាមបណ្ដាឆ្នាំនីមួយៗ ដែលនឹងផ្ដល់ធាតុចូលយ៉ាងសំខាន់អំពីបញ្ហា តម្រូវការរបស់ប្រជាពលរដ្ឋដល់ក្រុមប្រឹក្សាស្រុក ខេត្ត ហើយក្រុមប្រឹក្សាស្រុក ខេត្តត្រូវពិចារណា និងឆ្លើយតបនឹងបញ្ហា តម្រូវការទាំងនោះព្រមទាំងត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ។

គម្រោង សកម្មភាពវិនិយោគ គឺជាគម្រោង សកម្មភាពត្រូវចំណាយមូលនិធិដោយមានពេលចាប់ផ្ដើម និងពេលបញ្ចប់ច្បាស់លាស់ ដែលរៀបចំឡើងដើម្បីបង្កើតទ្រព្យសម្បត្តិសាធារណៈ(ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងអរូបវន្ត) និងសេវានានាសម្រាប់ឆ្លើយតបតាមតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ។

## ២. គោលការណ៍

យោងតាមមាត្រា៥ នៃអនុក្រឹត្យលេខ២១៩អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ត្រូវផ្អែកលើគោលការណ៍សំខាន់ដូចខាងក្រោម ៖

១. ការចែករំលែកព័ត៌មាន
២. តម្លាភាព
៣. សង្គតិភាព និងសុខដុមនីយកម្ម
៤. ការចូលរួមពិគ្រោះយោបល់ជាទូទៅ
៥. ការឆ្លើយតបនឹងតម្រូវការ
៦. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
៧. ប្រសិទ្ធភាព និងសុក្រឹតភាពសេដ្ឋកិច្ច និងសង្គម
៨. ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន
៩. ការធានាសមធម៌។

## ៣. យន្តការ និងភារកិច្ច

យន្តការ ដែលទទួលខុសត្រូវក្នុងការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ គឺ ៖

### ៣.១. ក្រុមប្រឹក្សាឃុំ មានភារកិច្ច ៖

- ពិនិត្យ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ដោយធានាឲ្យមានភាពគ្រប់ជ្រុងជ្រោយ និងឆ្លើយតប នឹងសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋដូចជា ស្ត្រី កុមារ ជនពិការ យុវជន និងជនងាយរងគ្រោះ។ល។
- ពិនិត្យ និងអនុម័តលើរាល់ការកែតម្រូវកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ក្នុងករណីចាំបាច់
- តាមដាន និងវាយតម្លៃអំពីលទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ។

**៣.២. មេឃុំ** មានភារកិច្ច ៖

- ដឹកនាំការងារកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ
- ដាក់សេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ជូនទៅក្រុមប្រឹក្សាឃុំដើម្បីពិនិត្យ និងអនុម័ត។

**៣.៣. គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ (គ.ផ.ថ)** មានភារកិច្ច ៖

- ជួយមេឃុំ ក្នុងការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ដោយអនុវត្តតាមបែបបទនីតិវិធីដូចមានកំណត់ក្នុងសេចក្តីណែនាំបច្ចេកទេសនេះ
- ជួយមេឃុំ ក្នុងការរៀបចំថវិកាប្រចាំឆ្នាំរបស់ឃុំ។

យន្តការទាំងបីខាងលើ គឺជាយន្តការស្នូលក្នុងការចូលរួម និងទទួលខុសត្រូវផ្ទាល់លើការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ។ ជាមួយគ្នានេះ ដើម្បីធានាឲ្យកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំមានគុណភាព នោះចាំបាច់ត្រូវមានយន្តការគាំទ្រ ដែលមាន ៖

**៣.៤. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ (គ.ក.ន.ក)** មានភារកិច្ច ៖

- ចូលរួមផ្តល់ព័ត៌មាន និងការពារខ្លឹមសារការងារក្នុងដែនសមត្ថកិច្ចខ្លួននៅក្នុងដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ
- សហការបំពេញការងារតាមសំណូមពរពី គ.ផ.ថ ដើម្បីកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ។

**៣.៥. មន្ទីរផែនការខេត្ត** មានភារកិច្ច ៖

- គាំទ្របច្ចេកទេសកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ដូចជា ការងារស្រង់ទិន្នន័យពីមូលដ្ឋានភូមិ ឃុំ ការងារចងក្រងកម្រងព័ត៌មានស្ថានភាពឃុំប្រចាំឆ្នាំ ឯកសារពិន្ទុវិស័យ និងគាំទ្រការងាររៀបចំ និងសម្របសម្រួលក្នុងសិក្ខាសាលាសមាហរណកម្មនៅស្រុក។
- សហការជាមួយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត និងទីចាត់ការផែនការ និងវិនិយោគខេត្ត ក្នុងការបណ្តុះបណ្តាលអំពីបច្ចេកទេសកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ការប្រើប្រាស់ទិន្នន័យ និងបច្ចេកទេសតាមដាន និងវាយតម្លៃលទ្ធផលអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ។
- សហការផ្តល់ការគាំទ្របច្ចេកទេសអំពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ និងការតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ដល់សមាជិកក្រុមប្រឹក្សាឃុំ ស្មៀនឃុំ និងបុគ្គលិកសំខាន់ៗរបស់ឃុំ តាមសំណើពីអ្នកពាក់ព័ន្ធ។

**៣.៦. ទីចាត់ការផែនការ និងវិនិយោគខេត្ត** មានភារកិច្ច ៖

- ផ្តល់ការបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សាឃុំ គ.ផ.ថ និងអ្នកពាក់ព័ន្ធអំពីនីតិវិធីកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ដោយមានកិច្ចសហការជាមួយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត មន្ទីរផែនការខេត្ត និងឬអង្គភាពជំនាញ ក្នុងករណីចាំបាច់។
- ជំរុញ និងគាំទ្រការប្រមូល និងរក្សាសៀវភៅកម្មវិធីវិនិយោគទុកជាឯកសារ
- ជួយក្រុមប្រឹក្សាឃុំ ក្នុងការរៀបចំ អនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ តាមដាន និងវាយតម្លៃអំពីលទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ។

**៣.៧. ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់** មានភារកិច្ច ៖

- ជួយក្រុមប្រឹក្សាឃុំ ក្នុងការវិភាគ វាយតម្លៃ និងរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ
- សហការគាំទ្រក្រុមប្រឹក្សាឃុំ ក្នុងការរៀបចំថវិកាឃុំ
- សហការពិនិត្យ និងលើកអនុសាសន៍ជូនអភិបាលខេត្ត អំពីការធ្វើអនុលោមភាពថវិកាឃុំ
- សម្របសម្រួល និងប្រមូលឯកសារបញ្ជូនទៅអង្គភាពពាក់ព័ន្ធ
- សិក្សាវាយតម្លៃ និងលើកយោបល់អំពីសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ និងតម្រូវការគាំទ្រ
- ជួយក្រុមប្រឹក្សាឃុំ ក្នុងការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់ឃុំ
- គាំទ្រក្រុមប្រឹក្សាឃុំក្នុងការរៀបចំ ការកសាង និងការអនុវត្តកម្មវិធីវិនិយោគឃុំ
- ជួយក្រុមប្រឹក្សាឃុំ ក្នុងការពិនិត្យ និងវាយតម្លៃការប្រើប្រាស់មូលនិធិវិនិយោគឃុំ ។

**៣.៨. ការិយាល័យផែនការស្រុក** មានភារកិច្ច ៖

- ជួយសម្របសម្រួល និងជំរុញអាជ្ញាធរភូមិ ឃុំ ក្នុងការស្រង់ទិន្នន័យមូលដ្ឋានភូមិ ឃុំ
- ជួយ គ.ផ.ថ ក្នុងការវិភាគព័ត៌មានស្ថានភាព និងពិន្ទុវិស័យភូមិ ឃុំ
- ជួយឃុំក្នុងការរៀបចំបណ្ដាឧបករណ៏សម្រាប់ចូលរួមសិក្ខាសាលាសមាហរណកម្មនៅស្រុក។

**៣.៩. មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធនានាថ្នាក់ខេត្ត** មានភារកិច្ច ៖

- ទទួលខុសត្រូវផ្ដល់ជំនួយបច្ចេកទេសដែលពាក់ព័ន្ធនឹងជំនាញរបស់ខ្លួនដល់ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ដូចជា យេនឌ័រ ការប្រែប្រួលអាកាសធាតុ ពិការភាព។ល។
- ផ្ដល់ការគាំទ្រគម្រោង សកម្មភាពវិនិយោគនានារបស់ឃុំ នៅក្នុងសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ស្រុក
- ជួយរដ្ឋបាលឃុំ ក្នុងការរៀបចំ និងអនុវត្តគម្រោង សកម្មភាពនានារបស់ឃុំ ។

**៣.១០. អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា** មានភារកិច្ច ៖

- ចូលរួមជាតំណាងឲ្យផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធណាមួយជាក់លាក់ ដូចជា តំណាងឲ្យស្ត្រី កុមារ យុវជន ជនក្រីក្រ ជនជាតិដើមភាគតិច។ល។
- ចូលរួមផ្ដល់ចំណេះដឹង និងគំនិតល្អៗក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ
- ចូលរួមក្នុងការពិភាក្សា និងពិគ្រោះយោបល់នានាដែលពាក់ព័ន្ធនឹងដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ
- ផ្ដល់ការគាំទ្រគម្រោង សកម្មភាពវិនិយោគនានារបស់ឃុំ ក្នុងសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ស្រុក។

**៣.១១. ប្រជាពលរដ្ឋ**

ក្នុងដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ប្រជាពលរដ្ឋក្នុងឃុំ គប្បីត្រូវបានចូលរួមក្នុងកិច្ចប្រជុំ ពិគ្រោះយោបល់ កំណត់បញ្ហា និងតម្រូវការអាទិភាពនានាក្នុងសមហគមន៍ និងមូលដ្ឋានខ្លួនទៅតាមស្ថានភាពជាក់ស្ដែងរបស់សាមីខ្លួននីមួយៗ។

# ផ្នែកទី២

# ទម្រង់សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

## ១. គ្របមុខ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កម្មវិធីវិនិយោគបីឆ្នាំរំកិល

# ២០.... - ២០....

# ឃុំ ...........ស្រុក...........ខេត្ត.....

បានទទួលការអនុម័តពីក្រុមប្រឹក្សាឃុំ
ក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញ លើកទី ថ្ងៃទី ខែ ឆ្នាំ២០...

## ២. មាតិកានៃសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

**សេចក្ដីសម្រេចស្ដីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ**

**អារម្ភកថា**

**សេចក្ដីផ្ដើម**

**ផែនទីឃុំ**

**ជំពូកទី១ ÷ ស្ថានភាពទូទៅ និងបញ្ហាប្រឈមក្នុងឃុំ**

១.១. សេចក្ដីសង្ខេបទិន្នន័យចម្បងក្នុងឃុំ

១.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

- ផ្នែកសេដ្ឋកិច្ច
- ផ្នែកសង្គមកិច្ច
- ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- ផ្នែករដ្ឋបាល និងសន្ដិសុខសណ្ដាប់ធ្នាប់សាធារណៈ

**ជំពូកទី២ ÷ គម្រោង សកម្មភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ**

២.១. តារាងសង្ខេបប្រភពមូលនិធិ

២.២. តារាងគម្រោង សកម្មភាពកំពុងដំណើរការ

២.៣. តារាងគម្រោង សកម្មភាពមានថវិកាគាំទ្រ

២.៤. តារាងគម្រោង សកម្មភាពអាទិភាពមិនទាន់មានថវិកាគាំទ្រ

២.៥. តារាងកម្មវិធីប្រតិបត្តិការសេវារដ្ឋបាល

២.៦. តារាងការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា

**ជំពូកទី៣ ÷ ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ**

៣.១. ក្របខ័ណ្ឌតាមដាន និងវាយតម្លៃ

៣.២. ការបែងចែកភារកិច្ចរបស់អ្នកពាក់ព័ន្ធក្នុងការតាមដាន និងវាយតម្លៃ

៣.៣. របាយការណ៍ស្ដីពីលទ្ធផលតាមដាន និងវាយតម្លៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

**ឧបសម្ព័ន្ធ**

## ៣. សេចក្តីពន្យល់អំពីបណ្តាសមាសធាតុក្នុងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

### សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

បន្ទាប់ពីទំព័រក្របសៀវភៅ គឺសេចក្តីសម្រេច។ សេចក្តីសម្រេច គឺជាលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាឃុំ។ ខ្លឹមសារសំខាន់ៗដែលត្រូវបញ្ចូលក្នុងសេចក្តីសម្រេច រួមមាន ការចូលជាធរមាននៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំដែលបានអនុម័តដោយក្រុមប្រឹក្សាឃុំ ការណែនាំដល់មេឃុំក្នុងការផ្សព្វផ្សាយ ការអនុវត្ត ការតាមដាន និងការវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ។ សេចក្តីសម្រេចនេះ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាឃុំ។

### អារម្ភកថា

អារម្ភកថា គឺជាអត្ថបទបង្ហាញពីសារប្រយោជន៍នៃកម្មវិធីវិនិយោគបីឆ្នាំរំកិល ការថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល និងសេចក្តីសង្ឃឹមថានឹងទទួលបានការគាំទ្រពីអ្នកពាក់ព័ន្ធ(អារម្ភកថា មិនគួរសរសេរវែងពេក ត្រឹមមួយទំព័រគឺជាការប្រសើរ)។ អារម្ភកថា ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាឃុំ។

### សេចក្តីផ្តើម

សេចក្តីផ្តើម ត្រូវសរសេរពីវឌ្ឍនភាពនៅក្នុងឃុំ និងមូលហេតុដែលនាំឲ្យមានការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ព្រមទាំងគោលបំណង និងសង្ខេបពីដំណើរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល (សេចក្តីផ្តើមគួរសរសេរខ្លីដែរ)។

### ផែនទី

ជាផែនទីឃុំ ដែលបង្ហាញពីលក្ខណៈភូមិសាស្ត្រ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ និងទីតាំងរដ្ឋបាលក្នុងឃុំ។ ផែនទីនេះរៀបចំលើក្រដាសទំហំA៣ និងប្រើនិមិត្តសញ្ញាតាងឱ្យវត្ថុកំពុងមានក្នុងឃុំដូចជា និមិត្តសញ្ញានៃប្រព័ន្ធផ្លូវថ្នល់ ស្ពាន លូរំដោះទឹក ប្រព័ន្ធប្រឡាយទឹក ទីតាំងរដ្ឋបាល ទីតាំងសាលារៀន ទីតាំងផ្តល់សេវាសុខភាពសាធារណៈ ទីតាំងសាសនា វាលស្រែ ធនធានធម្មជាតិ ។ល។

## ជំពូកទី១ ÷ ស្ថានភាពទូទៅ និងបញ្ហាប្រឈមក្នុងឃុំ

### ១.១. សេចក្តីសង្ខេបទិន្នន័យចម្បងៗរបស់ឃុំ

តារាងសង្ខេបទិន្នន័យចម្បងៗរបស់ឃុំ

| ល.រ | បរិយាយ | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... |
|---|---|---|---|---|---|---|
| **ព័ត៌មានទូទៅ** | | | | | | |
| ១ | ផ្ទៃដីឃុំ (គ.ម$^២$) | | | | | |
| ២ | ចំនួនភូមិ | | | | | |
| ៣ | ចំនួនគ្រួសារ | | | | | |
| ៤ | %មេគ្រួសារជាស្ត្រី | | | | | |
| ៥ | ចំនួនប្រជាជនសរុប | | | | | |

| ល.រ | បរិយាយ | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... |
|---|---|---|---|---|---|---|
| ៦ | ចំនួនស្រី | | | | | |
| ៧ | ចំនួនប្រុស | | | | | |
| ៨ | %អ្នកមានអាយុពី០-១៧ឆ្នាំ | | | | | |
| ៩ | %អ្នកមានអាយុពី១៨-៦០ឆ្នាំ | | | | | |
| ១០ | %អ្នកមានអាយុពី៦១ឆ្នាំឡើង | | | | | |
| ១១ | កំណើនប្រជាជនប្រចាំឆ្នាំ(%) | | | | | |
| ១២ | អត្រាភាពក្រីក្រ(%) | | | | | |
| ១៣ | %អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម | | | | | |
| ១៤ | %អ្នកមានមុខរបរចម្បងផ្នែកសិប្បកម្ម | | | | | |
| ១៥ | %អ្នកមានមុខរបរចម្បងផ្នែកសេវាកម្ម | | | | | |
| ១៦ | %មនុស្សទៅរកការងារធ្វើនៅក្នុងប្រទេស | | | | | |
| ១៧ | %មនុស្សទៅរកការងារធ្វើនៅក្រៅប្រទេស | | | | | |
| ១៨ | %ខ្នងផ្ទះមានអគ្គិសនីប្រើប្រាស់ | | | | | |
| **អប់រំ** | | | | | | |
| ១៩ | %កុមារអាយុ៣-៥ឆ្នាំបានចូលរៀន | | | | | |
| ២០ | %កុមារអាយុ៦ឆ្នាំបានចូលរៀន | | | | | |
| ២១ | %កុមារអាយុ៦-១១ឆ្នាំបានចូលរៀន | | | | | |
| ២២ | %កុមារអាយុ១២-១៤ឆ្នាំនៅរៀន | | | | | |
| ២៣ | %អ្នកចេះអក្សរអាយុ១៥-១៧ឆ្នាំ | | | | | |
| ២៤ | %អ្នកចេះអក្សរអាយុ១៨-៤៥ឆ្នាំ | | | | | |
| **សុខភាព** | | | | | | |
| ២៥ | ចំនួនមណ្ឌលសុខភាព | | | | | |
| ២៦ | %ស្ត្រីសម្រាលកូនដោយឆ្មបពេទ្យ | | | | | |
| ២៧ | អត្រាស្លាប់របស់មាតាក្រោយពេលសម្រាល (០-១ខែ)ក្នុង១ពាន់កំណើត | | | | | |
| ២៨ | អត្រាស្លាប់របស់កុមារក្រោយពេលកើត (០-១ខែ)ក្នុង១ពាន់កំណើត | | | | | |
| ២៩ | %កុមារអាយុពី៩-១២ខែបានចាក់ថ្នាំ បង្កាគ្រប់ចំនួន | | | | | |
| ៣០ | ចំនួនគ្រួសារមានសមាជិកកើតជំងឺអេដស៍ | | | | | |
| **ភាពងាយរងគ្រោះ** | | | | | | |
| ៣១ | ចំនួនជនពិការ | | | | | |
| ៣២ | %ជនពិការអាយុ១៨ឆ្នាំឡើងមិនអាចរកចំណូលបាន | | | | | |
| ៣៣ | ចំនួនកុមារកំព្រាឪពុកម្តាយស្លាប់ដោយជំងឺអេដស៍ | | | | | |
| ៣៤ | ចំនួនចាស់ជរាគ្មានទីពឹង(អាយុ៦១ឆ្នាំឡើង) | | | | | |
| **ធនធានធម្មជាតិ បរិស្ថាន និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ** | | | | | | |
| ៣៥ | ចំនួនគ្រួសាររងគ្រោះដោយសារខ្យល់កន្ត្រាក់ ព្យុះ | | | | | |
| ៣៦ | ចំនួនគ្រួសាររងគ្រោះដោយដោយសារទឹកជំនន់ | | | | | |
| ៣៧ | ចំនួនគ្រួសាររងគ្រោះដោយគ្រោះរាំងស្ងួត | | | | | |
| ៣៨ | %គ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះ | | | | | |
| ៣៩ | %គ្រួសារមានទឹកស្អាតប្រើប្រាស់ | | | | | |
| ក្នុង | %គ្រួសារមានទឹកម៉ាស៊ីនប្រើប្រាស់ | | | | | |

| ល.រ | បរិយាយ | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... |
|---|---|---|---|---|---|---|
| នោះ | %គ្រួសារមានទឹកអណ្តូងស្នប់ឬអណ្តូងចំរុះ | | | | | |
| | %គ្រួសារប្រើទឹកអណ្តូងជីកមានការការពារ | | | | | |
| | %គ្រួសារប្រើទឹកភ្លៀងមានការការពារ | | | | | |
| ៤០ | %គ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | | | | | |
| **រដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | | |
| ៤១ | %កុមារបានចុះសំបុត្រកំណើត(០-៣០ថ្ងៃ) | | | | | |
| ៤២ | ចំនួនគ្រួសារមានអំពើហិង្សាក្នុងគ្រួសារ | | | | | |
| ៤៣ | ចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ | | | | | |
| ៤៤ | ចំនួនអ្នកស្លាប់ដោយអំពើហិង្សានានា | | | | | |
| ៤៥ | ចំនួនគ្រួសារមានសមាជិកប្រើប្រាស់គ្រឿងញៀន | | | | | |

## ១.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមក្នុងឃុំ

ផ្នែកនេះ ត្រូវអធិប្បាយ និងសសេរតាមបែបវិភាគអំពីបច្ចុប្បន្នភាពនៃស្ថានភាពនានា និងកំណត់យកដំណោះស្រាយបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។ ការអធិប្បាយ និងសសេរនេះត្រូវធ្វើឡើងតាមលំដាប់លំដោយ ដោយផ្តើមពីស្ថានភាពសេដ្ឋកិច្ចទៅស្ថានភាពសង្គមកិច្ច ស្ថានភាពប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន ស្ថានភាពគ្រប់គ្រងគ្រោះមហន្តរាយ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ រហូតដល់ស្ថានភាពគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ (ឧបសម្ព័ន្ធទី៦)។ គ.ផ.ថ សរសេរស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមរបស់ឃុំ ដោយផ្អែកលើព័ត៌មានស្តីពីលទ្ធផលនៃការវិភាគពិន្ទុវិស័យ និងស្ថានភាពឃុំ។

## ជំពូកទី២ ÷ គម្រោង សកម្មភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

ជំពូកនេះ ត្រូវផ្តើមដោយអត្ថបទដែលបរិយាយសង្ខេបពីតម្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍនៅឆ្នាំខាងមុខ និងបន្ទាប់មកត្រូវបង្ហាញបណ្តាតារាងនៃគម្រោង សកម្មភាពវិនិយោគបីឆ្នាំរំកិលរបស់ឃុំដែលមានជាអាទិ៍ ៖

### តារាង២.១. ការសង្ខេបប្រភពមូលនិធិឆ្នាំ..........

| ល.រ | ស្ថាប័ន | ចំនួនគម្រោង សកម្មភាព | សរុបតម្លៃគម្រោង សកម្មភាព(លានរៀល) | ប្រភព មូលនិធិ | ចំនួនគម្រោង សកម្មភាព | តម្លៃគម្រោង (លានរៀល) |
|---|---|---|---|---|---|---|
| ១ | រដ្ឋបាលឃុំ | | | ឃុំ | | |
| | | | | ដៃគូអភិ. | | |
| | | | | សប្បុរសជន | | |
| ២ | ការគាំទ្រពីបណ្តាមន្ទីរ អង្គភាព | | | | | |
| ២.១ | មន្ទីរ... | | | មន្ទីរ | | |
| | | | | ដៃគូអភិ. | | |
| ២.២ | មន្ទីរ... | | | មន្ទីរ | | |
| | | | | ដៃគូអភិ. | | |
| ២. | មន្ទីរ... | | | | | |
| | | | | | | |

| ល.រ | ស្ថាប័ន | ចំនួនគម្រោងសកម្មភាព | សរុបតម្លៃគម្រោងសកម្មភាព(លានរៀល) | ប្រភពមូលនិធិ | ចំនួនគម្រោងសកម្មភាព | តម្លៃគម្រោង(លានរៀល) |
|---|---|---|---|---|---|---|
| សរុបមន្ទីរ អង្គភាព | | | | មន្ទីរ | | |
| | | | | ដៃគូរអភិ. | | |
| ៣ | ការគាំទ្រពីអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធ | | | | | |
| ៣.១. | អង្គការ.. | | | | | |
| ៣.២. | អង្គការ.. | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| សរុបអង្គការ ដៃគូ... | | | | | | |
| **សរុបរួម** (1+2+3) | | | | | | |

## តារាង២.២. គម្រោង សកម្មភាពឃុំកំពុងដំណើរការ

| ល.រ | ឈ្មោះគម្រោង | ឆ្លើយតបគោលដៅ | ទីតាំងគម្រោង | លទ្ធផលគ្រោង | | រយៈពេលអនុវត្ត | តម្លៃគម្រោង | ប្រភពមូលនិធិ | កម្រិតទុនវិនិយោគ(លានរៀល) | | | | អង្គភាពអនុវត្ត | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | | | ២.. | ២.. | ២.. | សរុប | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និង ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |

**កំណត់សម្គាល់ ៖** ជាតារាងដែលបង្ហាញពីប្រភេទគម្រោង សកម្មភាពកំពុងអនុវត្តក្នុងឆ្នាំរៀបចំកម្មវិធីវិនិយោគ ឬឆ្នាំសារពើពន្ធថវិកា ហើយនឹងត្រូវបន្តអនុវត្តនៅឆ្នាំមុខទៀត។

## តារាង២.៣. គម្រោង សកម្មភាពវិនិយោគឃុំដែលមានថវិកាគាំទ្រ

| ល.រ | ឈ្មោះគម្រោង | ឆ្លើយតប | ទីតាំង | លទ្ធផលគ្រោង | | រយៈពេល | តម្លៃ | ប្រភព | កម្រិតទុនវិនិយោគ(លានរៀល) | | | | អង្គភាព | កំណត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | គោលដៅ | គម្រោង | បរិមាណ | ឯកតា | អនុវត្ត | គម្រោង | មូលនិធិ | ២.. | ២.. | ២.. | សរុប | អនុវត្ត | សម្គាល់ |
| **គម្រោង សកម្មភាពប្រើប្រាស់មូលនិធិឃុំ** | | | | | | | | | | | | | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និង ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| **គម្រោង សកម្មភាពដែលទទួលបានការសន្យាគាំទ្រមូលនិធិពីអ្នកពាក់ព័ន្ធ** | | | | | | | | | | | | | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និង ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |

**កំណត់សម្គាល់ ៖** ជាតារាងដែលបង្ហាញពីប្រភេទគម្រោង សកម្មភាពដែលប្រើប្រាស់មូលនិធិឃុំ និងប្រើប្រាស់មូលនិធិដែលទទួលបានសន្យាគាំទ្រពីមន្ទីរ អង្គភាព អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា។

## តារាង២.៤. គម្រោង សកម្មភាពអាទិភាពឃុំដែលមិនទាន់មានថវិកាគាំទ្រ

| ល.រ | ឈ្មោះគម្រោង | ឆ្លើយតបគោលដៅ | ទីតាំងគម្រោង | លទ្ធផលគ្រោង | | រយៈពេលអនុវត្ត | អ្នកទទួលផលផ្ទាល់ | | ចំណាយប៉ាន់ស្មាន (លានរៀល) |
|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

## តារាង២.៥. កម្មវិធីប្រតិបត្តិការសេវារដ្ឋបាល ឆ្នាំ.....

| ល.រ | ប្រភេទសេវា | លទ្ធផលគ្រោង | | ផ្សេងៗ |
|---|---|---|---|---|
| | | បរិមាណ | ឯកតា | |
| | | | | |
| | | | | |
| | | | | |
| | | | | |

**កំណត់សម្គាល់ ៖** កម្មវិធីប្រតិបត្តិការសេវារដ្ឋបាលរបស់ឃុំ គឺជាសកម្មភាពផ្តល់សេវារដ្ឋបាល ដែលផ្តោតលើសេវារដ្ឋបាលនានាជាប្រចាំរបស់រដ្ឋបាលឃុំជូនប្រជាពលរដ្ឋរបស់ខ្លួន ដោយមានរួមបញ្ចូលទាំងការអនុវត្តមុខងារ និងធនធាននានាដែលរដ្ឋបាលឃុំបានទទួលពីថ្នាក់ជាតិ និងឬរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងៗទៀត។

## តារាង២.៦. ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋបាលឃុំ ឆ្នាំ....

| ល.រ | ប្រភេទលិខិតបទដ្ឋានគតិយុត្ត | លទ្ធផលគ្រោង | | ផ្សេងៗ |
|---|---|---|---|---|
| | | បរិមាណ | ឯកតា | |
| | | | | |
| | | | | |
| | | | | |
| | | | | |

**កំណត់សម្គាល់ ៖** មុនបង្ហាញតារាងខាងលើ គ.ផ.ថ ត្រូវបរិយាយសង្ខេបពីស្ថានភាពនានា ដែលតម្រូវឲ្យរដ្ឋបាលឃុំរៀបចំ និងដាក់ឲ្យអនុវត្តលិខិតបទដ្ឋានគតិយុត្តនានា។

## ជំពូកទី៣ ÷ ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល គឺជាសកម្មភាពដែលផ្តោតលើការសន្និដ្ឋានពីស្ថានភាព និងលទ្ធផលនៃការអនុវត្ត ៖

- គម្រោង សកម្មភាពកំពុងដំណើរការ
- គម្រោង សកម្មភាពដែលមានថវិកាគាំទ្រ
- គម្រោង សកម្មភាពអាទិភាពដែលមិនទាន់មានថវិកាគាំទ្រ
- តើមានការគាំទ្រគម្រោង សកម្មភាពថ្មីបន្ថែមក្រៅពីគម្រោង សកម្មភាពដែលមិនទាន់មានការសន្យាគាំទ្រ ឬទេ? ។ល។
- ការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តនានា
- ការផ្តល់សេវារដ្ឋបាល

**តារាងតាមដានការអនុវត្តគម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ**

| ល.រ | ឈ្មោះគម្រោង | គ្រោង/ជាក់ស្តែង | លទ្ធផល | | រយៈពេលអនុវត្ត | តម្លៃគម្រោង | អង្គភាពអនុវត្ត | % នៃការសម្រេច | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | | | | |
| **គម្រោងរបស់រដ្ឋបាលឃុំ** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **អង្គភាព**.... | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **អង្គភាព**.... | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **ការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលឃុំ** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |

គម្រោងដែលត្រូវស្រង់បញ្ចូលក្នុងតារាងខាងលើ គឺ ៖

- គម្រោង សកម្មភាពដែលមានថវិកាគាំទ្រ និង
- គម្រោង សកម្មភាពកំពុងដំណើរការ។

# ផ្នែកទី៣

# វិធីសាស្ត្ររៀបចំ

# និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

# ជំហានទី១
# ការប្រមូលព័ត៌មានស្តីពីតម្រូវការ
# របស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

**គោលបំណង**

គោលបំណងនៃជំហានទី១នេះ គឺដើម្បីប្រមូលព័ត៌មានបឋមស្តីពីតម្រូវការអភិវឌ្ឍន៍នានារបស់មូលដ្ឋាន សម្រាប់ប្រើប្រាស់ជាធាតុចូលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាខេត្ត គម្រោងថវិកាប្រចាំឆ្នាំ និងសម្រាប់ការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ស្រុក និងខេត្ត។

**លទ្ធផលរំពឹងទុក**

បញ្ជីគម្រោង សកម្មភាពដែលមានតម្លៃប៉ាន់ស្មានទាំងផ្នែករូបវន្ត អរូបវន្តជាតម្រូវការអភិវឌ្ឍន៍ក្នុងមូលដ្ឋានឃុំនៅឆ្នាំខាងមុខ ត្រូវបានផ្ញើទៅក្រុមការងារកសាងផែនការស្រុក ដើម្បីធ្វើការសម្រិតសម្រាំងរួចផ្ញើទៅខេត្តសម្រាប់ធ្វើជាធាតុចូលក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងយុទ្ធសាស្ត្រថវិកាខេត្ត។

**ដំណើរការ**

បន្ទាប់ពីចូលរួមប្រជុំណែនាំអំពីការប្រមូលតម្រូវការអាទិភាពនៅថ្នាក់ស្រុក មេឃុំត្រូវណែនាំឲ្យគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ (គ.ផ.ថ) ឲ្យចាប់ផ្តើមដំណើរការរៀបចំតម្រូវការសម្រាប់អភិវឌ្ឍន៍មូលដ្ឋានឃុំខ្លួន ដោយ ៖

ក. គ.ផ.ថ រៀបចំប្រជុំ ដែលមានសមាជិក សមាជិកា គ.ផ.ថ ស្មៀនឃុំ ប្រធានភូមិ ឬតំណាងភូមិទាំងអស់ក្នុងឃុំ ជនបង្គោលនានាក្នុងឃុំ ក្រុមការងារគណនេយ្យភាពសង្គម (បើមាន) ក្រុមយុវជន តំណាងការិយាល័យជំនាញ អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានាតាមការស្ម័គ្រចិត្តចូលរួម ដើម្បីពិនិត្យ និងវិភាគលើស្ថានភាពទូទៅនៅក្នុងឃុំ។ នៅពេលពិនិត្យ និងវិភាគស្ថានភាពឃុំ គ.ផ.ថ ត្រូវប្រើឯកសារព័ត៌មាននានាដូចខាងក្រោម ៖

- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា
- ក្របខ័ណ្ឌអភិវឌ្ឍន៍ប្រាំឆ្នាំរបស់រដ្ឋបាលខេត្ត និងរដ្ឋបាលស្រុក
- តារាងបញ្ហា តម្រូវការ និងដំណោះស្រាយកាលពីឆ្នាំកន្លងទៅ
- ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចឃុំ (រៀបចំដោយមន្ទីរផែនការខេត្ត)
- ពិន្ទុវិស័យឃុំ (រៀបចំដោយមន្ទីរផែនការខេត្ត)
- ផែនទីរដ្ឋបាលឃុំ និងផែនទីសេវាសង្គមឃុំ (បើមាន) និងព័ត៌មានផ្សេងៗទៀតតាមការចាំបាច់។

តាមការពិនិត្យ និងវិភាគស្ថានភាព (ឧបសម្ព័ន្ធទី២ និងទី៧ នៅក្នុងផ្នែកទី៤) គ.ផ.ថ និងអង្គប្រជុំទាំងមូលកំណត់អំពីបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋ និងឈានដល់ការឯកភាពគ្នាលើការកំណត់យកបញ្ហា ទីតាំងនៃបញ្ហា មូលហេតុ តម្រូវការ និងដំណោះស្រាយនៅក្នុងឃុំ។ ខ្លឹមសារដែលបានឯកភាពនោះ ត្រូវស្រង់បញ្ចូលក្នុងតារាងបញ្ហា តម្រូវការ និងដំណោះស្រាយ ( *ជាលទ្ធផលការងារដំបូងបង្អស់នៅថ្នាក់ឃុំ* )។

តារាងបញ្ហា តម្រូវការ និងដំណោះស្រាយ

| បញ្ហា | ទីតាំងនៃបញ្ហា | មូលហេតុនៃបញ្ហា | តម្រូវការ | ដំណោះស្រាយ | ផ្សេងៗ |
| --- | --- | --- | --- | --- | --- |
| | | | | | |
| | | | | | |
| | | | | | |

**ខ.** ផ្អែកតាមតារាងខាងលើនេះ មេភូមិនីមួយៗស្រង់យកបញ្ហា តម្រូវការ និងដំណោះស្រាយដែលពាក់ព័ន្ធនៅតាមភូមិរៀងៗខ្លួន ទៅបង្ហាញ និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងភូមិខ្លួន។ មេភូមិនីមួយៗត្រូវខិតខំជួប និងពិភាក្សាជាមួយតំណាងគ្រួសារប្រជាពលរដ្ឋឲ្យបានចំនួន៦០ភាគរយនៃចំនួនគ្រួសារសរុបក្នុងភូមិ (ប្រជាពលរដ្ឋទាំងនោះមាន ប្រុស ស្រី តំណាងក្រុមជនងាយរងគ្រោះ និងកុមារ និងជនជាតិដើមភាគតិច ពិសេសត្រូវលើកទឹកចិត្តស្ត្រី និងក្រុមជនងាយរងគ្រោះឲ្យមានការចូលរួមបានច្រើន)។

**គ.** មេភូមិទាំងអស់ត្រូវយកលទ្ធផលនៃការជួប និងពិភាក្សាជាមួយប្រជាពលរដ្ឋខ្លួនមកសាលាឃុំ ដើម្បី គ.ផ.ថ ធ្វើការប្រជុំបូកសរុប ផ្ទៀងផ្ទាត់ និងកែសម្រួលតារាងបញ្ហា តម្រូវការ និងដំណោះស្រាយដែល*ជាលទ្ធផលការងារដំបូងបង្អស់នៅថ្នាក់ឃុំ* រួចបំប្លែងបញ្ហា តម្រូវការ និងដំណោះស្រាយទាំងនោះទៅជាគម្រោង សកម្មភាព រួចស្រង់ចូលក្នុងតារាង១.១.ក តាមផ្នែក និងតាមលំដាប់អាទិភាព (ឧបសម្ព័ន្ធទី១ ក្នុងផ្នែកទី៤)។ នៅក្នុងការចាត់អាទិភាពគម្រោងទាំងនេះ គ.ផ.ថ ត្រូវជានាថា គម្រោងដែលឆ្លើយតបទៅនឹងបញ្ហា យេនឌ័រ បរិយាប័ន្ន សមធម៌សង្គម និងបញ្ហាប្រែប្រួលអាកាសធាតុ ជាបញ្ហាអន្តរវិស័យ និងត្រូវបានយកចិត្តទុកដាក់មាននៅគ្រប់ផ្នែកទាំង៤។

**ឃ.** ជាមួយគ្នានេះ គ.ផ.ថ ត្រូវពិនិត្យ ពិចារណា និងកំណត់សកម្មភាពនានានៃការអនុវត្តមុខងារជាកាតព្វកិច្ចដែលរដ្ឋបាលឃុំបានទទួល និង ឬគម្រោងនានាដែលត្រូវប្រើប្រាស់មូលនិធិមានភ្ជាប់លក្ខខណ្ឌ។ បន្ទាប់មក គ.ផ.ថ ត្រូវស្រង់សកម្មភាព ឬគម្រោងទាំងនោះចូលក្នុងតារាង១.១.ក។

តារាង១.១.ក ៖ តម្រូវការគម្រោង សកម្មភាពអាទិភាព

| ល.រ | ឈ្មោះគម្រោង សកម្មភាព | ឆ្លើយតប គោលដៅ | ទី តាំង | លទ្ធផល | | រយៈ ពេល | អ្នកទទួលផល | | តម្លៃ ប៉ាន់ស្មាន | ផ្សេងៗ |
| --- | --- | --- | --- | --- | --- | --- | --- | --- | --- | --- |
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | | |
| ១. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៣. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៤. ផ្នែករដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

ជាមួយគ្នានេះ គ.ផ.ថ ក៏ត្រូវពិចារណាលើតម្រូវការគម្រោងជាអាទិភាពដែលសល់ពីឆ្នាំកន្លងមក។ ប្រសិនបើគម្រោងទាំងនោះនៅតែជាតម្រូវការអាទិភាព គ.ផ.ថ ត្រូវស្រង់បញ្ចូលក្នុងតារាង១.១.ក។

ផ្អែកតាមការណែនាំរបស់ក្រុមការងារកសាងផែនការស្រុក គ.ផ.ថ ត្រូវរៀបចំ និងបំពេញទម្រង់ទី១ (របស់ស្រុក) ដោយផ្អែកលើតារាង១.១.ក និងត្រូវកំណត់គម្រោងអាទិភាពណាខ្លះដែលត្រូវអនុវត្តដោយរដ្ឋបាលឃុំ និងគម្រោងអាទិភាពណាខ្លះដែលរដ្ឋបាលឃុំត្រូវស្នើសុំបញ្ចូលក្នុងកម្មវិធីវិនិយោគស្រុក។ មេឃុំត្រូវផ្ញើទម្រង់ទី១នេះ ទៅក្រុមការងារកសាងផែនការស្រុកតាមកាលបរិច្ឆេទដែលបានកំណត់។

### ទម្រង់ទី១ ៖ ធាតុចូលអំពីការវិភាគស្ថានភាព និងតម្រូវការអភិវឌ្ឍន៍

**ក). ការវិភាគស្ថានភាព**

- ចំណុចខ្លាំង
- ចំណុចខ្សោយ/បញ្ហាប្រឈម
- បញ្ហាអាទិភាពសំខាន់ៗដែលត្រូវដោះស្រាយចំពោះមុខ។

**ខ). តម្រូវការគម្រោង សកម្មភាពជាអាទិភាព**

| ល.រ | ឈ្មោះគម្រោង | គោលដៅ | ទីតាំង | លទ្ធផលគ្រោង | | រយៈពេល | អ្នកទទួលផល | | តម្លៃប៉ាន់ស្មាន | អង្គភាពស្នើ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | | |
| **គម្រោងដែលឃុំ ឬអង្គភាពសាមីអាចមានលទ្ធភាពអនុវត្ត** | | | | | | | | | | |
| ១. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៣. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៤. ផ្នែករដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| **គម្រោងដែលឃុំ ឬអង្គភាពស្នើសុំបញ្ចូលទៅក្នុងកម្មវិធីវិនិយោគស្រុក** | | | | | | | | | | |
| ១. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៣. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៤. ផ្នែករដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

ថ្ងៃទី................. ខែ............. ឆ្នាំ២០..........
អ្នករៀបចំ

បានឃើញ និងឯកភាព
ថ្ងៃទី................. ខែ............. ឆ្នាំ២០..........
**មេឃុំ**

## ជំហានទី២
## ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

**គោលបំណង**

គោលបំណងនៃជំហានទី២នេះ គឺការរៀបចំ និងចងក្រងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំដោយមានភាពជាក់លាក់ មានការចូលរួម អាចអនុវត្តបាន និងមានសង្គតិភាពជាមួយនឹងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំ។

**លទ្ធផលរំពឹងទុក**

សេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ត្រូវបានបញ្ចប់ និងដាក់ជូនក្រុមប្រឹក្សាឃុំដើម្បីពិនិត្យ និងអនុម័ត។

**ដំណើរការ**

ក្រោយពីបានចូលរួមការផ្សព្វផ្សាយពីសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅស្រុក មេឃុំត្រូវណែនាំ គ.ផ.ថ ឲ្យចាប់ផ្តើមដំណើរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំរបស់ខ្លួន។

**សកម្មភាពសំខាន់ៗ ដែលត្រូវអនុវត្តក្នុងជំហានទី២ នេះមាន ៖**

២.១. ការពិនិត្យគម្រោង និងសកម្មភាពអាទិភាពឡើងវិញ

២.២. ការត្រៀមរៀបចំចូលរួមសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ស្រុក

២.៣. ការចូលរួមសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ស្រុក

២.៤. ការងារក្រោយសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ស្រុក

២.៥. ការរៀបចំតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ

២.៦. ការចងក្រងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

### ២.១. ការពិនិត្យគម្រោង និងសកម្មភាពអាទិភាពឡើងវិញ

បន្ទាប់ពីទទួលបានការណែនាំពីក្រុមការងារកសាងផែនការស្រុក គ.ផ.ថ ត្រូវចាប់ផ្តើមពិនិត្យមើលឡើងវិញនូវតម្រូវការគម្រោង សកម្មភាពអាទិភាពរបស់ឃុំ ដែលបានរៀបចំក្នុងជំហានទី១(តារាង ១.១.ក)។ ក្នុងការពិនិត្យឡើងវិញនេះ គ.ផ.ថ ត្រូវផ្ទៀងផ្ទាត់មើលថា តើមានគម្រោង សកម្មភាពណាខ្លះដែលនៅតែមានតម្រូវការជាអាទិភាព និងស្វែងរកមូលនិធិគាំទ្រ តើគម្រោង សកម្មភាពណាខ្លះលែងមានតម្រូវការចាំបាច់ រួចត្រូវស្រង់បញ្ចូលក្នុងតារាង ១.១.ខ។ ផ្អែកតាមតារាង ១.១.ខ គ.ផ.ថ ត្រូវរៀបចំបំពេញទម្រង់ទី៥របស់ស្រុក(តាមការណែនាំរបស់ក្រុមការងារកសាងផែនការស្រុក) រួចបញ្ជូនទៅក្រុមការងារកសាងផែនការស្រុក ដើម្បីក្រុមការងារកសាងផែនការស្រុកពិនិត្យ បូកសរុប និងចាត់ចែងផ្ញើទៅមន្ទីរផែនការខេត្តសម្រាប់រៀបចំឯកសារសម្រាប់ចូលរួមក្នុងការធ្វើវេទិកាពិគ្រោះយោបល់ ស្តីពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ខេត្ត។

សមាសភាពដែលត្រូវចូលរួមក្នុងពេលនេះមាន សមាជិក សមាជិកានៃ គ.ផ.ថ មេភូមិ និងជនបង្គោលសំខាន់ក្នុងឃុំ តាមការចាំបាច់។

តារាង១.១.ខ. តម្រូវការគម្រោង សកម្មភាពអាទិភាព

| ល.រ | ឈ្មោះគម្រោង សកម្មភាព | ឆ្លើយតប គោលដៅ | ទី តាំង | លទ្ធផល | | រយៈ ពេល | អ្នកទទួលផល | | តម្លៃ ប៉ាន់ស្មាន | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

មេឃុំត្រូវត្រៀមរៀបចំសម្រាប់ចូលរួមវេទិកាពិគ្រោះយោបល់នៅខេត្តតាមការអញ្ជើញពីខេត្ត ឬស្រុក (តាមការចាំបាច់)។

## ២.២. ការត្រៀមរៀបចំសម្រាប់ចូលរួមសិក្ខាសាលាសមាហរណកម្មនៅស្រុក

បន្ទាប់ពីទទួលបានព័ត៌មានអំពីលទ្ធភាពថវិកាដែលរដ្ឋបាលឃុំអាចមាន គ.ផ.ថ ត្រូវពិនិត្យមើលតារាង១.១.ខ ដែលបានរៀបចំខាងលើ ដើម្បីពិនិត្យមើលថាតើ ថវិការបស់រដ្ឋបាលឃុំមានចំនួនប៉ុន្មាន ហើយគួរគាំទ្រការអនុវត្តគម្រោងអាទិភាពណាខ្លះ?។ ក្នុងការពិនិត្យ និងសម្រេចជាបណ្តោះអាសន្ននេះលើការជ្រើសរើសគម្រោងអាទិភាព ដើម្បីប្រើប្រាស់ថវិកាឃុំនេះ គ.ផ.ថ ត្រូវ ៖

- ជ្រើសរើសគម្រោង ឬសកម្មភាពសម្រាប់ប្រើប្រាស់មូលនិធិមានភ្ជាប់លក្ខខណ្ឌ ដោយផ្អែកតាមអាទិភាពនៃសំណើគម្រោងក្នុងផ្នែកនីមួយៗ
- ជ្រើសរើសគម្រោង ឬសកម្មភាពដែលពាក់ព័ន្ធនឹងការអនុវត្តមុខងារជាកាតព្វកិច្ច
- បន្ទាប់មក បន្តជ្រើសរើសគម្រោងអាទិភាពនានា សម្រាប់ប្រើប្រាស់ថវិកាឃុំ ដែលមិនមានភ្ជាប់លក្ខខណ្ឌ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ ក្នុងការជ្រើសរើសនេះ គ.ផ.ថ គួរពិចារណាបន្ថែមទៀតលើ ៖
  - តុល្យភាពនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគម្រោងសេវានានា

- គម្រោងដែលឆ្លើយតបទៅនឹងតម្រូវការស្ត្រី កុមារ យុវជន ជនពិការ និងជនងាយរងគ្រោះ (បរិយាប័ន្ន និងសមធម៌សង្គម)
- គម្រោងដែលឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ល។

- បន្ទាប់មក គ.ផ.ថ ត្រូវរៀបចំតារាង១.១.គ.តម្រូវការគម្រោងអភិវឌ្ឍន៍សម្រាប់កម្មវិធីវិនិយោគឃុំ ដោយបន្ថែមប្រភពថវិកាតាមការពិនិត្យ ពិចារណា និងសម្រេចខាងលើ។

តារាង១.១.គ. តម្រូវការគម្រោង សកម្មភាពអាទិភាព

| ល.រ | ឈ្មោះគម្រោងសកម្មភាព | ឆ្លើយតបគោលដៅ | ទីតាំង | លទ្ធផល | | រយៈពេល | អ្នកទទួលផល | | តម្លៃប៉ាន់ស្មាន | ប្រភពមូលនិធិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

- បន្ទាប់ពីរៀបចំតារាង១.១.គ រួចហើយ គ.ផ.ថ ត្រូវបន្តរៀបចំរបាយការណ៍អនុវត្តគម្រោងសកម្មភាពនៃកម្មវិធីវិនិយោគ ដោយប្រៀបធៀបជាមួយគម្រោង សកម្មភាពដែលមានសន្យាមូលនិធិគាំទ្រអនុវត្តក្នុងឆ្នាំកន្លង មកតាមតារាង ១.២ ដូចខាងក្រោម ៖

**តារាង១.២ ៖ លទ្ធផលនៃការអនុវត្តគម្រោងក្នុងឆ្នាំ ......... ឃុំ ........**

| ល.រ | ឈ្មោះគម្រោង | ផ្នែក | ទីតាំង | លទ្ធផលគ្រោង | | តម្លៃប៉ាន់ស្មាន (លានរៀល) | អ្នកទទួលផល | | ប្រភពអ្នកគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | |
| **គម្រោងប្រើប្រាស់មូលនិធិឃុំ** | | | | | | | | | |
| ក. បានអនុវត្តរួចជាស្ថាពរ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ខ. កំពុងអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

| ល.រ | ឈ្មោះគម្រោង | ផ្នែក | ទីតាំង | លទ្ធផលគ្រោង | | តម្លៃប៉ាន់ស្មាន (លានរៀល) | អ្នកទទួលផល | | ប្រភព អ្នកគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | |
| គ. មិនបានអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| **គម្រោងឃុំដែលមានការសន្យាគាំទ្រ** | | | | | | | | | |
| ឃ. បានអនុវត្តរួចជាស្ថាពរ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ង. កំពុងអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ច. មិនបានអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| **គម្រោងដែលបានអនុវត្ត ដោយមិនមានការសន្យាគាំទ្រ** | | | | | | | | | |
| ឆ. បានអនុវត្តរួចជាស្ថាពរ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ជ. កំពុងអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

**កំណត់សម្គាល់ ៖**

- គម្រោងកំពុងអនុវត្ត គឺជាគម្រោងដែលមិនអាចអនុវត្តចប់ក្នុងឆ្នាំថវិកា និងត្រូវអនុវត្តបន្តនៅឆ្នាំបន្ទាប់
- គម្រោងបានអនុវត្តរួចជាស្ថាពរ គឺជាគម្រោងដែលបានបញ្ចប់១០០% ក្នុងឆ្នាំថវិកា។
- គម្រោងមិនបានអនុវត្ត គឺជាគម្រោងដែលមានការសន្យាគាំទ្រមូលនិធិ ប៉ុន្តែមិនបានអនុវត្តរហូតដល់ដាច់ឆ្នាំថវិកា (គម្រោងប្រភេទនេះ បើនៅមានការសន្យាគាំទ្រ នឹងក្លាយជាគម្រោងមានការសន្យានៅឆ្នាំបន្ទាប់)។

បន្ទាប់ពីបានរៀបចំកែសម្រួលរួច មេឃុំត្រូវផ្ញើតារាង១.១.គ និងតារាង១.២ ទៅមន្ទីរផែនការខេត្ត តាមរយៈរដ្ឋបាលស្រុក ដើម្បីរៀបចំឯកសារសម្រាប់ជួយរដ្ឋបាលស្រុកធ្វើសិក្ខាសាលាសមាហរណកម្មកម្មវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ស្រុក។

## ២.៣. ការចូលរួមសិក្ខាសាលាសមាហរណកម្មនៅស្រុក

តាមការអញ្ជើញពីរដ្ឋបាលស្រុកឲ្យចូលរួមសិក្ខាសាលាសមាហរណកម្មកម្មវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ស្រុក មេឃុំត្រូវ ៖

- ចាត់ស្មៀនឃុំ សមាជិកក្រុមប្រឹក្សាឃុំ១ ឬ២រូប និងមេភូមិមួយចំនួនត្រៀមចូលរួម តាមការចាំបាច់
- រៀបចំឯកសារសម្រាប់បង្ហាញ (ផែនទីភូមិសាស្ត្រសេដ្ឋកិច្ចសង្គម តារាង១.១.គ និងតារាង១.២ សម្រាប់បិទបង្ហាញ និងបង្ហាញក្នុងសិក្ខាសាលា)

- ត្រៀមធ្វើបទបង្ហាញខ្លឹមសារតារាង១.១.គ និងតារាង១.២ ជូនអង្គសិក្ខាសាលា
- ចាត់តំណាងឃុំមួយរូបចាំបំភ្លឺខ្លឹមសារបណ្តាតារាងដែលបានដាក់តាំងបង្ហាញក្នុងបរិវេណទីតាំងសិក្ខាសាលា
- ឯកសារសម្រាប់ចុះកិច្ចព្រមព្រៀងបណ្តោះអាសន្ន។ល។

ក្នុងអំឡុងពេលសិក្ខាសាលា តាមការរៀបចំរបស់អ្នកសម្របសម្រួល តំណាងប្រតិភូឃុំមួយរូប (ធម្មតាគឺមេឃុំ) ជាអ្នកឡើងបង្ហាញបំភ្លឺអំពីខ្លឹមសារ អត្ថន័យរបស់តារាង១.១.គ និងតារាង១.២របស់ឃុំខ្លួន ដើម្បីសុំការគាំទ្រថវិកា និងបច្ចេកទេសអនុវត្តន៍ពីអ្នកគាំទ្រ ឬដៃគូអភិវឌ្ឍន៍។

## ២.៤. ការងារក្រោយពីសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ស្រុក

- មេឃុំត្រូវណែនាំឲ្យ គ.ផ.ថ ពិនិត្យ និងកែសម្រួលតារាង ១.១.គ ដោយផ្អែកលើលទ្ធផលពីសិក្ខាសាលាសមាហរណកម្មនៅស្រុក និងការឯកភាពយោបល់ក្នុង គ.ផ.ថ លើការប្រើប្រាស់មូលនិធិរបស់ឃុំ (ប្រសិនបើមានការផ្លាស់ប្តូរ) សម្រាប់អនុវត្តគម្រោង សកម្មភាពអាទិភាពដែលគ្មានការសន្យាគាំទ្រ។
- បន្ទាប់ពីបញ្ចប់ការកែសម្រួលតារាង ១.១.គ មេភូមិនីមួយៗត្រូវស្រង់យកឈ្មោះគម្រោងសកម្មភាពដែលស្ថិតនៅតាមភូមិរៀងៗខ្លួនចេញពីតារាង១.១.គ ដើម្បីយកទៅបង្ហាញ និងពិភាក្សា ពិគ្រោះយោបល់ និងស្រង់យកមតិយោបល់ពីប្រជាពលរដ្ឋក្នុងភូមិខ្លួន។
- ក្រោយពីបានពិភាក្សា ស្រង់មតិ យោបល់ពីប្រជាពលរដ្ឋក្នុងភូមិខ្លួន មេភូមិត្រូវយកយោបល់ទាំងអស់(អាចមានទាំងការចង់បានគម្រោង សកម្មភាពថ្មីៗបន្ថែមទៀត) មកឃុំ ដើម្បី គ.ផ.ថ និងអ្នកពាក់ព័ន្ធនានាពិនិត្យ និងកែតម្រូវ រួចបំពេញតារាងព័ន្ធនានាដូចខាងក្រោម ៖
  - តារាង២.១ ៖ សង្ខេបប្រភពមូលនិធិ
  - តារាង២.២ ៖ គម្រោង សកម្មភាពកំពុងដំណើរការ (ផ្អែកតាមតារាង១.២)
  - តារាង២.៣ ៖ គម្រោង សកម្មភាពឃុំ ដែលមានការសន្យាគាំទ្រថវិកា
  - តារាង២.៤ ៖ គម្រោង សកម្មភាពឃុំដែលមិនទាន់មានការសន្យាគាំទ្រថវិកា

  និងរៀបចំតារាង
  - តារាង ២.៥ ៖ កម្មវិធីប្រតិបត្តិការសេវារដ្ឋបាលរបស់ឃុំ ដោយរួមបញ្ចូលនូវសេវារដ្ឋបាលនានាដែលឃុំមាន និងឬសេវារដ្ឋបាលដែលរដ្ឋបាលឃុំបានទទួលពីការផ្ទេរមុខងារពីក្រសួង ស្ថាប័ន និងឬពីរដ្ឋបាលខេត្ត ឬស្រុក
  - តារាង ២.៦ ៖ ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋបាលឃុំ។

### ២.៥. ការរៀបចំតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ

ដើម្បីឲ្យការអនុវត្តការតាមដាន និងវាយតម្លៃការអនុវត្តគម្រោង សកម្មភាពក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំមានប្រសិទ្ធភាព និងមានប្រយោជន៍នោះ មេឃុំត្រូវណែនាំឲ្យ គ.ផ.ថ រៀបចំគោលការណ៍ និងនីតិវិធីប្រតិបត្តិការ ដែលមាន ៖

- ក្របខ័ណ្ឌតាមដាន វាយតម្លៃ ( យុទ្ធសាស្ត្រ វិធីសាស្ត្រ ផែនការសកម្មភាព )

- ការបែងចែកភារកិច្ចដល់អ្នកពាក់ព័ន្ធក្នុងការតាមដាន និងវាយតម្លៃ (យន្តការ ភារកិច្ច)
- តារាងតាមដានការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

**តារាងតាមដានការអនុវត្តគម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ**

| ល.រ | ឈ្មោះ គម្រោង | គ្រោង/ ជាក់ស្តែង | លទ្ធផល | | រយៈពេល អនុវត្ត | តម្លៃ គម្រោង | អង្គភាព អនុវត្ត | % នៃការ សម្រេច | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | | | | |
| **គម្រោងរបស់រដ្ឋបាលឃុំ** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **អង្គភាព**.... | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **អង្គភាព**.... | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **ការផ្តល់សេវារដ្ឋបាល** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **ការដាក់ចេញលិខិតបទដ្ឋាន** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |

គម្រោងដែលត្រូវស្រង់បញ្ចូលក្នុងតារាងខាងលើ គឺ ៖

- គម្រោងដែលមានការសន្យាគាំទ្រថវិកាអនុវត្ត និង
- គម្រោងកំពុងដំណើរការ។

## ២.៦. ការចងក្រងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

ក្នុងការចងក្រងសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ គ.ផ.ថ រៀបចំសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ដោយផ្អែកតាមមាតិកានៃសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ដោយត្រូវសរសេរបរិយាយ និងចងក្រងចេញជាសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ស្របតាមសេចក្តីពន្យល់ដែលមានក្នុងផ្អែកទី២នៃសេចក្តីណែនាំនេះ។

## ជំហានទី៣
## ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

**គោលបំណង**

គោលបំណងនៃជំហាននេះ គឺដើម្បីពិនិត្យ អនុម័ត និងផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ស្របតាមខ្លឹមសារក្នុងមាត្រា៦២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

**លទ្ធផលរំពឹងទុក**

កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ត្រូវបានចូលជាធរមាន និងមានតម្លៃគតិយុត្តក្នុងការប្រើប្រាស់។

**ដំណើរការ**

សកម្មភាពសំខាន់ក្នុងជំហានទី៣នេះ រួមមាន ៖

៣.១. កិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

៣.២. ការផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

### ៣.១. កិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

បន្ទាប់ពីទទួលបានសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ក្រុមប្រឹក្សាឃុំត្រូវរៀបចំកិច្ចប្រជុំពិនិត្យ និងអនុម័ត ក្នុងសម័យប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សាឃុំ។

ដើម្បីជានាភាពរលូន និងជោគជ័យក្នុងកិច្ចប្រជុំពិនិត្យ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ការងារដែលត្រូវធ្វើមានដូចខាងក្រោម ៖

**មុនកិច្ចប្រជុំ**

គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ(គ.ផ.ថ) ត្រូវរៀបចំ ៖

- របៀបវារៈនៃកិច្ចប្រជុំជូនប្រធានក្រុមប្រឹក្សាឃុំ ពិនិត្យ និងណែនាំ
- សង្ខេបខ្លឹមសារនៃសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ។

**ក្នុងពេលប្រជុំ**

**សមាសភាពចូលរួម**

- សមាជិកក្រុមប្រឹក្សាឃុំ
- គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ (គ.ផ.ថ)
- ស្មៀនឃុំ
- ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាក្នុងនាមជាអ្នកសង្កេតការណ៍។

**ដំណើរការកិច្ចប្រជុំ**

សកម្មភាពក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំនេះ រួមមាន ៖

- ប្រធានក្រុមប្រឹក្សាឃុំ បើកកិច្ចប្រជុំ និងដឹកនាំអង្គប្រជុំ
- ស្មៀនឃុំបង្ហាញពីរបាយការណ៍សង្ខេបនៃដំណើរការរៀបចំកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ
- គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ (គ.ផ.ថ) បង្ហាញខ្លឹមសារសំខាន់ៗនៃសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

- សមាជិកក្រុមប្រឹក្សាឃុំពិនិត្យ ពិភាក្សាលើខ្លឹមសារនៃសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ (សំណួរគន្លឹះមានក្នុងឧបសម្ព័ន្ធទី៤ ក្នុងផ្នែកទី៤នៃសេចក្តីណែនាំនេះ)
- ក្រុមប្រឹក្សាឃុំ អនុម័តលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ តាមគោលការណ៍ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

**ក្រោយកិច្ចប្រជុំ**

បន្ទាប់ពីកិច្ចប្រជុំក្រុមប្រឹក្សាឃុំ គ.ផ.ថ ត្រូវ ៖

- ធ្វើការកែតម្រូវបណ្តាចំណុចក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ (តាមការសម្រេចក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាឃុំ)
- តាក់តែងសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ
- យកសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ដែលបានកែតម្រូវចុងក្រោយបង្អស់ និងសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ជូនប្រធានក្រុមប្រឹក្សាឃុំពិនិត្យ និងចុះហត្ថលេខា។

### ៣.២. ការបោះពុម្ព និងផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

### ក. ការបោះពុម្ពសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

មេឃុំពិនិត្យ និងណែនាំការបោះពុម្ពសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ។

### ខ. ការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

- តាមការឯកភាពយោបល់រវាងក្រុមប្រឹក្សាឃុំ និងមេឃុំ សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំត្រូវតម្កល់ទុកនៅសាលាឃុំ និងផ្ញើជូនទៅការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ទីចាត់ការផែនការ និងវិនិយោគខេត្ត មន្ទីរផែនការខេត្ត និងជូនទៅក្រសួង ស្ថាប័ន ឬអ្នកពាក់ព័ន្ធនានា តាមសំណើ។
- ជាមួយនឹងការផ្សព្វផ្សាយតាមការចែកសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ មេឃុំគប្បីណែនាំឲ្យមានការផ្សព្វផ្សាយខ្លឹមសារកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងឃុំ និងអ្នកពាក់ព័ន្ធ ដូចជា ផ្សព្វផ្សាយក្នុងកិច្ចប្រជុំនានា ក្នុងវេទិកាសាធារណៈ តាមសារព័ត៌មាន វិទ្យុក្នុងស្រុក និងតាមមធ្យោបាយផ្សេងៗទៀតដែលអាចធ្វើបាន។ល។
- មេឃុំត្រូវរៀបចំកិច្ចផ្សព្វផ្សាយអំពីគម្រោងប្រើប្រាស់មូលនិធិឃុំ ស្រុក ខេត្ត និងគម្រោងប្រើប្រាស់ប្រភពមូលនិធិផ្សេងទៀត ដែលត្រូវអនុវត្តក្នុងដែនដីរដ្ឋបាលឃុំ ដើម្បីឲ្យប្រជាពលរដ្ឋក្នុងឃុំបានដឹង (សេចក្តីលម្អិតនៃការរៀបចំប្រជុំផ្សព្វផ្សាយនេះ មាននៅក្នុងឧបសម្ព័ន្ធទី៥ ក្នុងផ្នែកទី៤នៃសេចក្តីណែនាំនេះ)។

# ផ្នែកទី៤

# ឧបសម្ព័ន្ធជាជំនួយស្មារតីនៅពេល

# រៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

**ឧបសម្ព័ន្ធទី១**

## វិធីសាស្ត្រចាត់អាទិភាព

ការចាត់អាទិភាពគម្រោង សកម្មភាព មានវិធីសាស្ត្របួន (០៤) ដែលគេនិយមប្រើ គឺ ១).វិធី សាស្ត្រផ្តល់ពិន្ទុផ្អែកលើលក្ខណៈវិនិច្ឆ័យ ២).វិធីសាស្ត្រផ្ទុផ្ទង ៣).វិធីសាស្ត្រជ្រើសរើសដោយដាក់ពិន្ទុ តាមជម្រើស និង ៤).វិធីសាស្ត្រ Pay off matrix។ ក្នុងចំណោមវិធីសាស្ត្រទាំងនេះ វិធីសាស្ត្រផ្តល់ពិន្ទុ ផ្អែកតាមលក្ខណៈវិនិច្ឆ័យ គឺជាវិធីសាស្ត្រសាមញ្ញ។

ក្នុងការអនុវត្តវិធីសាស្ត្រនេះ គ.ផ.ថ ឬអ្នកពាក់ព័ន្ធនានាអាចពិចារណា និងអនុវត្តតាមចំណុចនីមួយៗ ដូចខាងក្រោម ៖

- ស្រង់ជម្រើសនានា ដែលត្រូវចាត់អាទិភាពចូលក្នុងតារាង
- ពិភាក្សា និងកំណត់លក្ខណៈវិនិច្ឆ័យនានា។ ជាទូទៅលក្ខណៈវិនិច្ឆ័យមានការប្រែប្រួលទៅតាមលក្ខណៈនៃជម្រើស ឬបញ្ហា ឬដំណោះស្រាយ។ ជាទូទៅលក្ខណៈវិនិច្ឆ័យដែលចាំបាច់ គួរតែមាននៅគ្រប់ជម្រើស ឬដំណោះស្រាយ គឺការឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ក្រុមងាយរងគ្រោះដាក់លាក់ណាមួយ និងភាពសមធម៌។
- ពិនិត្យជម្រើសនីមួយៗម្តងមួយៗ ដោយធៀបជាមួយលក្ខណៈវិនិច្ឆ័យដែលបានកំណត់។ ពិន្ទុដែលទទួលបានពីការប្រៀបធៀបត្រូវកំណត់ជាលេខ។ ពិន្ទុទាបជាងគេ០១ ហើយពិន្ទុខ្ពស់ជាងគេ គឺជាស្មើនឹងចំនួនជម្រើសសរុប ។

**ឧទាហរណ៍ ៖** អំពីតារាងនៃវិធីផ្តល់ពិន្ទុផ្អែកលើលក្ខណៈវិនិច្ឆ័យ

| ជម្រើស | លក្ខណៈវិនិច្ឆ័យ | | | | | សរុបពិន្ទុ |
|---|---|---|---|---|---|---|
| | ការឆ្លើយតបតម្រូវការ | ការនិយមចូលចិត្ត | ការថែទាំ | សមធម៌ | ប្រសិទ្ធភាពតម្លៃ | |
| គម្រោង "ក" | 2 | 3 | 5 | 1 | 5 | 16 |
| គម្រោង "ខ" | 4 | 5 | 4 | 3 | 4 | 20 |
| គម្រោង "គ" | 3 | 3 | 3 | 2 | 3 | 14 |
| គម្រោង "ឃ" | 5 | 1 | 2 | 4 | 1 | 13 |
| គម្រោង "ង" | 1 | 1 | 2 | 1 | 1 | 6 |

តាមរយៈឧបករណ៍នេះ ក្រុមការងារបានកំណត់យកគម្រោងចំនួន០៥ និងលក្ខណៈវិនិច្ឆ័យចំនួន០៥ មកធ្វើជាសមាសធាតុសម្រាប់រៀបលំដាប់ថ្នាក់អាទិភាពនៃគម្រោង។ តាមការផ្តល់ពិន្ទុក្នុងតារាងខាងលើ យើងឃើញថា ៖

| ជំរើស | អាទិភាព |
|---|---|
| គម្រោង "ខ" | ១ |
| គម្រោង "ក" | ២ |
| គម្រោង "គ" | ៣ |
| គម្រោង "ឃ" | ៤ |
| គម្រោង "ង" | ៥ |

**ឧបសម្ព័ន្ធទី២**

## វិធីសាស្ត្រវិភាគស្ថានភាព
## វិធីសាស្ត្រវិភាគឯកសារព័ត៌មានស្ថានភាព និងឯកសារពិន្ទុវិស័យ

ក្នុងការវិភាគស្ថានភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីកំណត់ពីតម្រូវការគម្រោងអាទិភាព គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ (គ.ផ.ថ) ត្រូវធ្វើការវិភាគ និងសន្ទតអំពីចំណុចខ្លាំង ចំណុចខ្សោយ របស់វិស័យនីមួយៗ ដោយផ្អែកលើទិន្នន័យភូមិ ទិន្នន័យឃុំ សង្កាត់ ឯកសារព័ត៌មានស្ថានភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងទិន្នន័យឬព័ត៌មាន (ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ពិន្ទុវិស័យ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ផែនទីសេវា សង្គម...) និងឧបករណ៍វិភាគផ្សេងៗ ដើម្បីកំណត់អំពីបញ្ហា មូលហេតុនៃបញ្ហា និងដំណោះស្រាយនានា។

ក្នុងការវិភាគដោយប្រើប្រាស់ឯកសារព័ត៌មានស្ថានភាព ពិន្ទុវិស័យ គ.ផ.ថ ត្រូវ៖

- ពិនិត្យមើលទិន្នន័យ ឬព័ត៌មានដែលមានក្នុងឯកសារព័ត៌មានស្ថានភាពម្តងមួយចំណុចៗ
- ផ្អែកលើទិន្នន័យ និងព័ត៌មាននីមួយៗ តើអ្វីជាបញ្ហាដែលមានការប្រឈមខ្លាំងដល់បុរស ស្ត្រី ជនពិការ កុមារ និងក្រុមជនងាយរងគ្រោះជាក់លាក់ណាមួយ ដែលត្រូវធ្វើការដោះស្រាយ ឬអន្តរាគមន៍?
- បន្ទាប់ពីកំណត់បញ្ហារួច ត្រូវធ្វើការពិភាក្សាដើម្បីកំណត់ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយ
- ស្រង់បញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយចូលក្នុង តារាងដូចខាងក្រោម។

**បញ្ហា តម្រូវការ និងដំណោះស្រាយ**

| បញ្ហា | ទីតាំងនៃបញ្ហា | មូលហេតុនៃបញ្ហា | តម្រូវការ | ដំណោះស្រាយ | ផ្សេងៗ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ក្រៅពីវិធីសាស្ត្រខាងលើនេះ ក្រុមការងារកសាងផែនការ ឬ គ.ផ.ថ អាចប្រើប្រាស់ឧបករណ៍ និងវិធីសាស្ត្រផ្សេងៗទៀតដូចជា ដើមឈើបញ្ហា ការវិភាគការប្រែប្រួលអាកាសធាតុ ស្វត ... តាមការចាំបាច់។

**ឧបសម្ព័ន្ធទី៣**

## សំណួរគន្លឹះសម្រាប់ក្រុមប្រឹក្សា
## ពិនិត្យ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល

ជាជំនួយស្មារតី ក្នុងការពិនិត្យ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ក្រុមប្រឹក្សាគប្បីយកចិត្តទុកដាក់លើចំណុចគន្លឹះនានា ដូចខាងក្រោម ៖

1. តើការរៀបចំសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្របតាមមាតិកាដែលបានកំណត់ក្នុងសេចក្តីណែនាំបច្ចេកទេសដែរឬទេ ?
2. តើដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល អនុវត្តតាម ជំហានដូចបានកំណត់ក្នុងសេចក្តីណែនាំបច្ចេកទេសឬទេ ?
3. តើមានការវិភាគស្ថានភាពជាក់ស្តែងដែរឬទេ ?
4. តើទិន្នន័យ និងព័ត៌មានដែលបានយកមកប្រើ គឺជាទិន្នន័យ និងព័ត៌មានដែលបានធ្វើបច្ចុប្បន្នភាពឬទេ ?
5. តើការវិភាគស្ថានភាព បានផ្តោតលើបញ្ហារបស់ស្ត្រី បុរស កុមារ ជនពិការ យុវជន ឬក្រុមជនងាយរងគ្រោះជាក់លាក់ឬទេ ?
6. តើការវិភាគស្ថានភាព បានផ្តោតលើបញ្ហាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុឬទេ ?
7. តើបានកំណត់អំពីបញ្ហាប្រឈម និងដំណោះស្រាយសមស្រប សម្រាប់ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ពិសេស ស្ត្រី បុរស កុមារ និងក្រុមជនងាយរងគ្រោះជាក់លាក់ឬទេ ?
8. ក្នុងការកំណត់តម្រូវការអភិវឌ្ឍន៍ តើមានការចូលរួមពីអ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋ ឬតំណាងប្រជាពលរដ្ឋឬទេ ?
9. តើគម្រោងវិនិយោគដែលបានរៀបចំ បានឆ្លើយតបទៅនឹងបញ្ហាប្រឈម ដូចរៀបរាប់នៅក្នុងការវិភាគស្ថានភាពឬទេ ?
10. តើគម្រោងអាទិភាពដែលមានថវិកាគាំទ្រ ឆ្លើយតបទៅនឹង តម្រូវការជាក់លាក់របស់ប្រជាពលរដ្ឋ ពិសេស ស្ត្រី ឬបុរស ឬកុមារ ឬជនពិការ ឬក្រុមជនងាយរងគ្រោះជាក់លាក់ណាមួយឬទេ ?
11. តើគម្រោង ឬសកម្មភាព និងកិច្ចប្រតិបត្តិការសេវារដ្ឋបាលនានា ឆ្លើយតបទៅនឹងក្របខ័ណ្ឌអភិវឌ្ឍឃុំ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានដែរឬទេ ?
12. តើជំពូកតាមដាន និងវាយតម្លៃបានកំណត់អំពីយន្តការ និង វិធីសាស្ត្រសម្រាប់ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគឬទេ ?
13. តើសេចក្តីព្រាងកម្មវិធីវិនិយោគ បានយកទៅពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធឬទេ ?
14. តើគម្រោងដែលមានថវិកាគាំទ្រ មានគម្រោងហេដ្ឋារចនា សម្ព័ន្ធរូបវន្តប៉ុន្មាន ? អរូបវន្តប៉ុន្មាន ?

**ឧបសម្ព័ន្ធទី៤**

## ការរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ

ដើម្បីជានាឲ្យមានការពង្រឹងប្រព័ន្ធគណនេយ្យភាពរវាងក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខេត្ត ចំពោះប្រជាពលរដ្ឋ ក្រុមការងារកសាងផែនការខេត្ត ស្រុក ត្រូវរៀបចំ និងផ្តល់ព័ត៌មានគម្រោង (គម្រោងកំពុងដំណើរការ និងគម្រោងមានថវិកាគាំទ្រ) របស់រដ្ឋបាលខ្លួនទៅឲ្យឃុំនីមួយៗ (គម្រោងដែលត្រូវអនុវត្តក្នុងដែនដីឃុំសាមីនីមួយៗ) ដើម្បីឲ្យឃុំអាចរៀបចំកិច្ចប្រជុំផ្សព្វផ្សាយគម្រោង វិនិយោគ ដែលមានថវិកាអនុវត្តទាំងនោះដល់ប្រជាពលរដ្ឋនៅក្នុងឃុំរបស់ខ្លួន។

កិច្ចប្រជុំផ្សព្វផ្សាយនេះ ត្រូវបង្ហាញអំពី ៖

- គម្រោងវិនិយោគរបស់ឃុំ
- គម្រោងវិនិយោគរបស់ស្រុក
- គម្រោងវិនិយោគរបស់ខេត្ត

សមាសភាពចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយ រួមមាន ៖

- ប្រជាពលរដ្ឋ
- សមាជិកក្រុមប្រឹក្សាឃុំ និង គ.ផ.ថ
- ស្មៀន ជំនួយការ និងជនបង្គោលនានារបស់ឃុំ
- គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ(គ.ក.ន.ក)
- ក្រុមយុវជន
- តំណាងរដ្ឋបាលស្រុក ខេត្ត
- អ្នកពាក់ព័ន្ធផ្សេងទៀត តាមការចាំបាច់។

**ដំណើរការ**

**ក. មុនពេលប្រជុំ**

- ទីចាត់ការផែនការ និងវិនិយោគខេត្ត សហការជាមួយមន្ទីរផែនការ និងការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ត្រូវផ្តល់ព័ត៌មានអំពីគម្រោងវិនិយោគរបស់ស្រុក និងខេត្ត ឲ្យដល់មេឃុំនីមួយៗ និងជួយមេឃុំក្នុងការរៀបចំតារាងគម្រោងវិនិយោគរបស់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវអនុវត្តក្នុងដែនដីឃុំនីមួយៗ ដើម្បីឲ្យឃុំយកព័ត៌មានគម្រោងទាំងនោះទៅបង្ហាញ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅក្នុងឃុំ។
- គ.ផ.ថ ត្រៀមរៀបចំសម្ភារៈ តារាងគម្រោងវិនិយោគ (គម្រោងដែលមានថវិកាគាំទ្រ គម្រោងកំពុងអនុវត្ត) តាមទម្រង់តារាងដូចខាងក្រោម ៖

គម្រោងវិនិយោគដែលត្រូវអនុវត្ត
ក្នុងដែនដីឃុំ................ សម្រាប់ឆ្នាំ..........

| ល.រ | ឈ្មោះគម្រោង | ទីតាំង | ប្រភពថវិកា | ស្ថានភាពគម្រោង | |
|---|---|---|---|---|---|
| | | | | កំពុងដំណើរការ | មានថវិកាគាំទ្រ |
| គម្រោងវិនិយោគរបស់ឃុំ | | | | | |
| | | | | | |
| | | | | | |
| គម្រោងវិនិយោគរបស់ស្រុក | | | | | |
| | | | | | |
| | | | | | |
| គម្រោងវិនិយោគរបស់ខេត្ត | | | | | |
| | | | | | |
| | | | | | |

- រៀបចំកម្មវិធីសម្រាប់ការផ្សព្វផ្សាយ
- បន្ទាប់ពីឯកភាពលើកម្មវិធីផ្សព្វផ្សាយ មេឃុំត្រូវជូនដំណឹងស្តីពីការផ្សព្វផ្សាយកម្មវិធីវិនិយោគឱ្យបានយ៉ាងតិច៣ថ្ងៃមុនកិច្ចប្រជុំ។ ការផ្សព្វផ្សាយអាចធ្វើនៅតាមភូមិនីមួយៗ ឬធ្វើការប្រមូលផ្តុំពីរ ឬបីភូមិ អាស្រ័យទៅតាមស្ថានភាព និងលទ្ធភាពជាក់ស្តែង។

## ខ. អំឡុងពេលប្រជុំ

- ក្នុងអំឡុងពេលនៃកិច្ចប្រជុំផ្សព្វផ្សាយ មេឃុំត្រូវធ្វើការបង្ហាញអំពីគម្រោងវិនិយោគដែលមានថវិកាគាំទ្រ និងគម្រោងវិនិយោគកំពុងដំណើរការរបស់ ៖
  - រដ្ឋបាលឃុំ
  - រដ្ឋបាលស្រុក និង
  - រដ្ឋបាលខេត្ត
- មេឃុំ ត្រូវបញ្ជាក់ជូនប្រជាពលរដ្ឋអំពីគម្រោងអាទិភាពនានាដែលប្រជាពលរដ្ឋបានស្នើឡើង តែមិនទាន់មានថវិកាអនុវត្ត ដោយត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ អំពីមូលហេតុដែលនាំឲ្យគម្រោងអាទិភាពមួយចំនួនមិនអាចអនុវត្តបានក្នុងឆ្នាំខាងមុខ។ ការពន្យល់ បកស្រាយ និងបង្ហាញមូលហេតុច្បាស់លាស់នេះ គឺជាការអនុវត្តគណនេយ្យភាពតាមបែបប្រជាធិបតេយ្យរបស់ក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ។
- គ.ផ.ថ ត្រូវកត់ត្រានូវគ្រប់យោបល់ទាំងអស់ដែលប្រជាពលរដ្ឋបានលើកឡើងឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។
- មុនពេលបញ្ចប់កិច្ចប្រជុំផ្សព្វផ្សាយ មេឃុំត្រូវមានសំណូមពរឲ្យប្រជាពលរដ្ឋចូលរួម សហការគាំទ្រក្នុងការអនុវត្ត និងតាមដានការអនុវត្តនូវគម្រោងទាំងអស់នោះ។

## គ. ក្រោយកិច្ចប្រជុំ

- គ.ផ.ថ ត្រូវធ្វើការបូកសរុបលទ្ធផលនៃការប្រជុំផ្សព្វផ្សាយ។
- ផ្តល់របាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំផ្សព្វផ្សាយ ជូនដល់រដ្ឋបាលស្រុក និងខេត្តដែលពាក់ព័ន្ធ។

**ឧបសម្ព័ន្ធទី៥**

## ឧបករណ៍
## វិភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ

ការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយទៅក្នុងកម្មវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្អែកលើសេចក្តីណែនាំបច្ចេកទេសស្តីពីការ រៀបចំកម្មវិធីវិនិយោគថ្នាក់ក្រោមជាតិ។ ដំណើរការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ ត្រូវអនុវត្តឡើងតាំងពីដំណាក់កាលដំបូងនៃការរៀបចំកម្មវិធី វិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

នៅក្នុងការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះ មហន្តរាយ ក្រុមការងារកសាងផែនការ គ.ផ.ថ និង ឬ អ្នកពាក់ព័ន្ធផ្សេងៗទៀត អាចប្រើប្រាស់ឧបករណ៍ នានា ដូចខាងក្រោម ៖

### ១). ឧបករណ៍ទី១ ៖ ការគូសផែនទីហានិភ័យនៃគ្រោះមហន្តរាយ

ការរៀបចំផែនទីនេះនឹងជួយកំណត់ពីមុខសញ្ញាហានិភ័យនៃគ្រោះមហន្តរាយ ដែលបានកើតឡើងក្នុងមូលដ្ឋាន។ ការគូសផែនទីនឹងជួយដល់អ្នករៀបចំផែនការក្នុងការកំណត់នូវទីតាំង និងស្ថានភាពនៃភាពងាយរងគ្រោះ ដើម្បីឈានទៅធ្វើការវិភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ ការគូសផែនទីនេះនឹងធ្វើឡើងនៅក្នុងកម្រិតឃុំ សង្កាត់ ដោយមានការចូលរួមពីសមាជិកក្រុមប្រឹក្សា គ.ក.ន.ក ប្រធានភូមិ និងអ្នកពាក់ព័ន្ធនានា ដោយប្រើប្រាស់ផែនទីរដ្ឋបាលឃុំជាគោល។

ការគូសផែនទីត្រូវធ្វើឡើងជា៤ជំហាន ដូចខាងក្រោម ៖

- **ជំហានទី១ ៖** គូសគំនូសទ្រង់ទ្រាយរបស់រដ្ឋបាលឃុំ សង្កាត់ កំណត់ព្រំប្រទល់រដ្ឋបាលភូមិ រួចហើយអ្នកចូលរួមគូសបន្ថែមនូវទីតាំងលក្ខណៈធម្មជាតិដូចជា ទន្លេ បឹង ព្រៃ តំបន់អភិរក្សជាដើម។
- **ជំហានទី២ ៖** គូសបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធថ្មីៗដែលមានក្នុងមូលដ្ឋានទៅក្នុងផែនទី ដូចជា ៖
  - ផ្លូវ
  - អគារសាធារណៈ (វត្ត អគាររដ្ឋបាល សាលារៀន មន្ទីរពេទ្យ...)
  - ទំនប់ទឹក អាងស្តុកទឹក ប្រព័ន្ធធារាសាស្ត្រ អណ្តូងទឹក និងស្រះ
  - ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី (ម៉ាស៊ីនភ្លើង, ឋាមពលកកើតឡើងវិញ...)
  - ទីតាំងចាក់សំរាម ប្រព័ន្ធលូ
  - បូជនីយដ្ឋាន ជាដើម
- **ជំហានទី៣ ៖** ក្នុងជំហាននេះ អ្នកចូលរួមគូសផែនទីបញ្ជាក់ពីទីតាំងដែលទទួលរងផលប៉ះពាល់ពីគ្រោះធម្មជាតិ ដោយប្រើប្រាស់គំនូសតាងផ្សេងៗគ្នា ឬប្រើប្រាស់ពណ៌ជាសញ្ញាតាមការឯកភាពគ្នាក្នុងក្រុម។ ផលប៉ះពាល់អាចមានដូចជា តំបន់ដែលរងផលប៉ះពាល់ពីទឹកជំនន់ គ្រោះរាំងស្ងួត ព្យុះសត្វល្អិតបំផ្លាញ ជំងឺរាតត្បាត ការឡើងកំដៅ និងតំបន់ឆ្នេរដែលមានរលកធំៗ ជាដើម។
- **ជំហានទី៤ ៖** អ្នកចូលរួមកំណត់ និងគូសលើផែនទីពីស្ថានភាពប្រែប្រួលនៃទិដ្ឋភាពពីមុន និងពេលបច្ចុប្បន្ន (ឧទាហរណ៍ ៖ ទំនប់តាមតំបន់ឆ្នេរ ការបាត់បង់ព្រៃ និងដីអភិរក្ស)។ ការប្រែប្រួលទាំងនេះអាចមានប្រភពខុសគ្នាៗដូចជា បណ្តាលមកពីការសម្រេចចិត្តផ្នែកនយោបាយ សង្គម សេដ្ឋ

កិច្ច ផលប៉ះពាល់ពីអាកាសធាតុ និងពីគ្រោះធម្មជាតិជាដើម។ ទោះជាមានហេតុផលខុសគ្នាក៏ដោយការប្រែប្រួលនៃបរិស្ថានធម្មជាតិ ក៏អាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការប្រែប្រួលអាកាសធាតុ ឬគ្រោះធម្មជាតិផងដែរ។

**តាមរយៈឧបករណ៍ទី១នេះ** អ្នកវិភាគអាចកំណត់បាននូវទីតាំងភូមិសាស្ត្រ ប្រភេទគ្រោះមហន្តរាយធម្មជាតិ ស្ថានភាពនៃការប្រែប្រួល និងមូលហេតុនានាដែលនាំឲ្យ មានការប្រែប្រួលស្ថានភាពគ្រោះធម្មជាតិតាមប្រភេទនីមួយៗ។ ឧបករណ៍ទី១នេះ នឹងត្រូវប្រើប្រាស់ជាមូលដ្ឋានក្នុងការអនុវត្ត ឧបករណ៍ផ្សេងៗទៀត។

## ២). ឧបករណ៍ទី២ ៖ ការវិភាគនិន្នាការ

ការវិភាគនិន្នាការ គឺជាឧបករណ៍សម្រាប់កំណត់នូវការប្រែប្រួលអាកាសធាតុសំខាន់ៗ និងព្រឹត្តការណ៍គ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុដែលកើតមានឡើង។ លទ្ធផលនៃការវិភាគនេះនឹងផ្តល់នូវព័ត៌មានអំពីគ្រោះមហន្តរាយអាកាសធាតុជាក់លាក់ និន្នាការនៃប្រភេទគ្រោះមហន្តរាយធម្មជាតិនីមួយៗ ភាពញឹកញាប់ ភាពធ្ងន់ធ្ងរ និងរបបនៃផលប៉ះពាល់។

ការអនុវត្តនូវឧបករណ៍វិភាគនិន្នាការនេះ ត្រូវធ្វើឡើងជាមួយប្រជាពលរដ្ឋ ដែលស្ថិតក្នុងតំបន់រងគ្រោះពីគ្រោះមហន្តរាយ (ផ្អែកលើផែនទីហានិភ័យគ្រោះមហន្តរាយ) ជនងាយរងគ្រោះ ស្ត្រី ចាស់ជរា និងជនក្រីក្រដោយបែងចែកជាក្រុមពិភាក្សាតូចៗយ៉ាងតិច៣ ដូចជាក្រុមស្ត្រី ក្រុមបុរស និងក្រុមអាជ្ញាធរ ឬច្រើនជាងនេះទៅតាមការចាំបាច់។ ការវិភាគធ្វើឡើងជា៣ជំហាន ដូចខាងក្រោម ៖

- **ជំហានទី១ ៖** អ្នកសម្របសម្រួលត្រូវសួរអំពីព្រឹត្តការណ៍គ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុ និងផលប៉ះពាល់ដែលពួកគេបានជួបប្រទះកន្លងមក ហើយយកទិន្នន័យនោះទៅបំពេញនៅក្នុងតារាងខាងក្រោមត្រង់ខ្ទង់ លក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស (ដូចមានក្នុងតារាងខាងក្រោម)។
- **ជំហានទី២ ៖** អ្នកសម្របសម្រួលបន្តសាកសួរដល់អ្នកចូលរួមធ្វើការចាត់ថ្នាក់ភាពងាយរងគ្រោះដែលបានជួបប្រទះតាមឆ្នាំ ដែលបានកំណត់ទៅតាមមុខសញ្ញានៃគ្រោះមហន្តរាយនីមួយៗ។ ក្នុងការធ្វើចំណាត់ថ្នាក់នេះត្រូវដាក់ពិន្ទុ កម្រិតរងគ្រោះពី១ ដល់៥ (១.កម្រិតរង គ្រោះទាបបំផុត និង៥. ជាកម្រិតរងគ្រោះធ្ងន់ធ្ងរបំផុត)។
- **ជំហានទី៣ ៖** បន្ទាប់ពីការដាក់ពិន្ទុកម្រិតភាពរងគ្រោះហើយ ត្រូវបន្តពិនិត្យមើលលើនិន្នាការនៃផលប៉ះពាល់ទៅតាមមុខសញ្ញានីមួយៗ ហើយស្វែងរកនូវមុខសញ្ញាគ្រោះថ្នាក់ណាមួយដែលកើតឡើងញឹកញាប់ និងកាន់តែធ្ងន់ធរ ដើម្បីធ្វើការវិភាគបន្តនៅក្នុងទម្រង់អក្សរ H។

តារាងវិភាគនិន្នាការ

| ប្រភេទគ្រោះធម្មជាតិ | និន្នាការ | | | | កំណត់សម្គាល់ |
|---|---|---|---|---|---|
| | ១៩៨០-៨៩ | ១៩៩០-៩៩ | ២០០០-០៩ | ២០១០-បច្ចុប្បន្ន | |
| • រាំងស្ងួត | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • រដូវប្រាំងអូស បន្លាយ (លើសពី៣សប្តាហ៍) | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ការខូតដំណាំ ដោយភាពរាំងស្ងួត | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ការខូតដំណាំ ដោយ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |

| ប្រភេទគ្រោះធម្មជាតិ | និន្នាការ | | | | កំណត់សម្គាល់ |
|---|---|---|---|---|---|
| | ១៩៨០-៨៩ | ១៩៩០-៩៩ | ២០០០-០៩ | ២០១០-បច្ចុប្បន្ន | |
| ទឹកជំនន់ | | | | | |
| • ការធ្លាក់ភ្លៀងខ្លាំង | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ការកើនឡើងកម្រិតទឹកជំនន់ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ការអូសបន្លាយ រយៈពេលទឹក ជំនន់ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ការប្រែប្រួល អំឡុងពេលរដូវ ប្រាំង - វស្សា | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ។ល។ | | | | | |

**កំណត់សម្គាល់**

ក្នុងការអនុវត្តជាក់ស្តែង អ្នកវិភាគត្រូវពិចារណាលើកំណត់សម្គាល់ដូចខាងក្រោម ៖

- ប្រភេទគ្រោះធម្មជាតិ ៖ អាស្រ័យលើប្រភេទគ្រោះធម្មជាតិដែលបានកើតមានឡើងជាក់ស្តែងនៅក្នុងមូលដ្ឋាននីមួយៗ។
- ឆ្នាំ ៖ អាចកំណត់ ឬបែងចែកតាមជំនាន់ ឬរបប ឬឆ្នាំ ឬតាមការកំណត់ផ្សេងៗទៀត ដែល ជាអាចឲ្យអ្នកចូលរួមងាយស្រួលក្នុងការរំលឹកឡើងវិញនូវនិន្នាការពាក់ព័ន្ធនឹងប្រភេទគ្រោះធម្មជាតិនីមួយៗ។

### ៣). ឧបករណ៍ទី៣ ៖ ការវិភាគតាមទម្រង់ H

ឧបករណ៍ទម្រង់អក្សរ "H" គឺជាឧបករណ៍វាយតម្លៃដោយមានការចូលរួម ដែលពង្រឹងបន្ថែមលើលទ្ធផលនៃការវិភាគនិន្នាការ ហើយឧបករណ៍នេះមានគោលបំណងកំណត់ភាពប្រែប្រួលសំខាន់នៃអាកាសធាតុ និងព្រឹត្តការណ៍គ្រោះមហន្តរាយអាកាសធាតុ ព្រមទាំងផលប៉ះពាល់ក្នុងមូលដ្ឋាននៅតំបន់ជាក់លាក់ណាមួយ។ លើសពីនេះ ឧបករណ៍នេះក៏ជួយសម្រួលផងដែរក្នុងការកំណត់វិធានការបន្សាំដែលសមស្របសម្រាប់សហគមន៍។ ក្នុងការអនុវត្តជំហាននេះ អ្នកវិភាគត្រូវអនុវត្តតាមជំហាននានា ដូចខាងក្រោម ៖

- **ជំហានទី១ "ការកំណត់ផលប៉ះពាល់នៃមុខសញ្ញាគ្រោះមហន្តរាយ"៖** សកម្មភាពក្នុងជំហាននេះ រួមមាន ៖
  - កំណត់ និងឯកភាពលើមុខសញ្ញា ឬប្រភេទគ្រោះមហន្តរាយធម្មជាតិ
  - វិភាគនិន្នាការនៃមុខសញ្ញា ឬប្រភេទគ្រោះមហន្តរាយធម្មជាតិ ដោយសួរសំណួរគន្លឹះ មួយចំនួន ដូចខាងក្រោម ៖
    + តើមានផលប៉ះពាល់អវិជ្ជមានអ្វីខ្លះ កើតចេញពីមុខសញ្ញានៃគ្រោះមហន្តរាយ?
    + តើមានដំណោះស្រាយអ្វីខ្លះ?
    + តើផលប៉ះពាល់ មានកម្រិតណា?
    + តើនៅក្នុងសហគមន៍មានធនធានអ្វីខ្លះ សម្រាប់ដោះស្រាយបញ្ហាប្រឈមផលប៉ះពាល់ទាំងនោះ?។ល។
  - បន្ទាប់ពីសួរសំណួរគន្លឹះនានាហើយ អ្នកសម្របសម្រួលត្រូវ ៖
    + ស្រង់នូវផលប៉ះពាល់អវិជ្ជមានដែលបានលើកឡើងដោយអ្នកចូលរួមទៅក្នុងផ្នែកខាងឆ្វេងនៃតារាងទម្រង់ H
    + ស្រង់ពីធនធានដែលមានក្នុងសហគន៍ដាក់នៅផ្នែកខាងស្តាំនៃតារាងទម្រង់ H

+ ស្រង់អំពីដំណោះស្រាយដែលបានលើកឡើងនៅផ្នែកកណ្តាលនៃតារាងទម្រង់ H

– បន្ទាប់មកទៀត អ្នកសម្របសម្រួលស្នើសុំឲ្យអ្នកចូលរួមវាយតម្លៃពីកម្រិតផលប៉ះពាល់នៃមុខសញ្ញាវងគ្រោះនោះចំពោះរូបគេ និងក្រុមគ្រួសារម្នាក់ម្តងៗ តាមរយៈការដាក់ពិន្ទុពី ១ជាកម្រិតទាប ដល់៥ដែលជាកម្រិតធ្ងន់ធ្ងរ។ រួចធ្វើការគណនាមធ្យមភាគពិន្ទុដែល អ្នកចូលរួមបានដាក់។

ការវិភាគតាមទម្រង់ H ទី១

បញ្ហា ៖ ....................................................

| ផលប៉ះពាល់ ៖ | ដំណោះស្រាយ<br><br>១ ២ ៣ ៤ ៥ | ធនធានដែលមាន ៖ |
|---|---|---|
| +<br>+<br>+ | +<br>+<br>+ | +<br>+<br>+ |

– បន្ទាប់ពីអ្នកចូលរួមនីមួយៗបានដាក់ពិន្ទុលើកម្រិតនៃផលប៉ះពាល់ហើយ អ្នកសម្របសម្រួលត្រូវបូកសរុប និងគិតមធ្យមភាគលើពិន្ទុដែលបានកំណត់។ ពិន្ទុមធ្យមភាគដែល បានកំណត់ត្រូវប្រើប្រាស់ជាសូចនាករសម្រាប់តាមដានអំពីវឌ្ឍនភាពនៃការឆ្លើយតបទៅ នឹងការបន្សុំាការប្រែប្រួលអាកាសធាតុ និងជាលក្ខណៈវិនិច្ឆ័យមួយសម្រាប់ចាត់អាទិភាព លើបញ្ហាដែលត្រូវដោះស្រាយ។

- **ជំហានទី២ "ការកំណត់ផលប៉ះពាល់ពីការកើនឡើងទ្វេដងនៃមុខសញ្ញាគ្រោះមហន្តរាយ"** ៖ នៅក្នុងជំហានទី២នេះ អ្នកសម្របសម្រួលលើកឡើងថា ប្រសិនបើមុខសញ្ញានៃគ្រោះមហន្តរាយ (មុខសញ្ញាដែលបានវិភាគក្នុងជំហានទី១) កើនឡើងកាន់តែញឹកញាប់ ឬកើនឡើងទ្វេដង តើប្រជាពលរដ្ឋម្នាក់ ឬគ្រួសារនីមួយៗនឹងទទួលផលប៉ះពាល់យ៉ាងដូចម្តេចខ្លះ? ហើយគួរត្រូវមានដំណោះស្រាយយ៉ាងដូចម្តេច? អ្នកសម្របសម្រួលកត់ត្រាចម្លើយរបស់អ្នកចូលរួមនៅក្នុងទម្រង់ H ដូចខាងក្រោម ៖

ការវិភាគតាមទម្រង់ H ទី២

បញ្ហា ៖ ....................................................

| ផលប៉ះពាល់ ៖ | ដំណោះស្រាយ ៖<br><br>១ ២ ៣ ៤ ៥ | |
|---|---|---|
| +<br>+<br>+ | +<br>+<br>+ | |

បន្ទាប់មក អ្នកសម្របសម្រួលស្នើឲ្យអ្នកចូលរួមដាក់ពិន្ទុលើកម្រិតផលប៉ះពាល់ ដូចជំហាន ទី១។ ទម្រង់អក្សរ Hទី២នេះនឹងជួយឲ្យអ្នកចូលរួមគិតប្រមាណទុកជាមុននូវភាពធ្ងន់ធ្ងរនៃអាកាសធាតុដែលអាចគម្រាមគំហែងដល់សហគមន៍ និងលើកយកដំណោះស្រាយកាន់តែមានប្រសិទ្ធភាពមួយកម្រិតថែមទៀត ក្នុងការបង្ការផលប៉ះពាល់ពីគ្រោះមហន្តរាយ កសាងភាពធន់ និងការបន្សុំាខ្លួនរបស់សហគមន៍។

- **ជំហានទី៣ "ការកំណត់កត្តារាំង" ៖** បន្ទាប់មកអ្នកសម្របសម្រួលបន្តពិភាក្សាអំពី ឧបសគ្គនានា ដែលអាចកើតមានឡើង ដោយប្រើឧបករណ៍ទម្រង់អក្សរ H ទី៣។ ក្នុងការប្រើប្រាស់ឧបករណ៍ H ទី៣នេះ អ្នកសម្រសបម្រួល ផ្តោតលើកត្តារាំងនានា ដែលប្រជាពលរដ្ឋ ឬសហគមន៍មិនអាចបន្សាំទៅនឹងមុខសញ្ញានៃគ្រោះមហន្តរាយដែលត្រូវបានលើកឡើងមកនោះ។ ចម្លើយរបស់អ្នកចូលរួមត្រូវកត់ត្រាទុកនៅផ្នែកកណ្តាលនៃតារាង ហើយអ្នកចូលរួមត្រូវដាក់ពិន្ទុនៃកម្រិតកត្តារាំងនោះម្នាក់ម្តងៗពីលេខ១ជាកម្រិតតិចតួច ដល់លេខ៥ជាកម្រិតធ្ងន់ធ្ងរ។ ចុងបញ្ចប់ត្រូវគណនានូវពិន្ទុមធ្យមភាគនៃការដាក់ពន្ទុរបស់អ្នកចូលរួម។

ការវិភាគតាមទម្រង់ H ទី៣




- **ជំហានទី៤ "ការកំណត់វិធានការ" ៖** បន្ទាប់មកអ្នកសម្របសម្រួលបន្តពិភាក្សាអំពីសកម្មភាព ឬវិធានការនានា ដែលអាចជួយឲ្យប្រជាពលរដ្ឋ និងគ្រួសារនីមួយៗអាចបន្សាំទៅនឹងមុខសញ្ញានៃមហន្តរាយធម្មជាតិ ដូចដែលបានវិភាគក្នុងជំហានទី៣ ដោយសួរសំណួរគន្លឹះ ថា ៖
  - តើមានវិធានការបន្សាំអ្វីខ្លះដែលអាចជួយបង្កើនភាពធនរបស់សហគមន៍បាន?
  - តើត្រូវធ្វើយ៉ាងដូចម្តេចខ្លះ ដើម្បីឲ្យទទួលបានពិន្ទុកាន់តែល្អជាងនេះ?

  ជាមួយគ្នានេះ អ្នកសម្របសម្រួលត្រូវស្រង់ចម្លើយនៃសំណួរទាំងនេះដាក់ក្នុងផ្នែកកណ្តាល នៃទម្រង់ H និងត្រូវស្រង់ដំណោះស្រាយនានាដែលបានកំណត់ក្នុងជំហានទី២ មកដាក់បញ្ចូល និងបន្ស៊ីជាមួយគ្នា។ ព្រមទាំងធ្វើការដាក់ពិន្ទុដោយឯកភាពគ្នាជាក្រុមលើការទុកចិត្តនៃគម្រោង ឬដំណោះស្រាយដែលបានលើកឡើង ពីពិន្ទុ១ ដែលពិន្ទុទុកចិត្តខ្លាំងដល់ពិន្ទុ៥ ជាពិន្ទុមិនទុកចិត្តសោះ។

  **ការគណនាពិន្ទុ៖**

  ការគណនាពិន្ទុមធ្យមភាគនៃទម្រង់Hនីមួយៗ ត្រូវយកពិន្ទុសរុប ចែកនឹងចំនួនអ្នកដាក់ពិន្ទុ ឬគណនាតាមមធ្យាបាយផ្សេងៗទៀតតាមការចាំបាច់។

- **ជំហានទី៥ "ការរៀបចំគម្រោង" ៖** ក្រោយពីបានពិភាក្សាតាមក្រុមរួចរាល់ហើយ អ្នកសម្របសម្រួលយកលទ្ធផលនៃការកិច្ចពិភាក្សាក្រុមទាំងអស់ដាក់បញ្ចូលគ្នា ដោយស្រង់យកនូវដំណោះស្រាយនានាដែលបានលើកឡើង មករៀបចំជាគម្រោងបន្សាំការប្រែប្រួលអាកាសធាតុ។ ចំណែកឯពិន្ទុនៃការពិភាក្សាក្នុងក្រុមនីមួយៗ ត្រូវយកមកបូកបញ្ចូលគ្នា ចែកនឹងចំនួនក្រុមពិភាក្សា នឹងបានជាពិន្ទុមធ្យមភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុក្នុងឃុំ សង្កាត់ ដែលត្រូវបានកំណត់ជាសូចនាករសម្រាប់តាមដានក្នុងឆ្នាំបន្ទាប់។ ក្រោយពីបានរៀបចំជាគម្រោងបន្សាំការប្រែប្រួលអាកាសធាតុរួចរាល់ហើយ អ្នកវិភាគត្រូវជួបប្រជុំគ្នាជាថ្មីដើម្បីធ្វើការចាត់ថ្នាក់ភាពងាយរងគ្រោះនៃគម្រោង ដោយប្រើប្រាស់ឧបករណ៍ទី៤។

**៤. ឧបករណ៍ទី៤ "ការធ្វើចំណាត់ថ្នាក់ភាពងាយរងគ្រោះនៃគម្រោង"**

ការចាត់ថ្នាក់ភាពងាយរងគ្រោះនៃគម្រោងដែលបានលើកឡើង គឺជាការចាំបាច់ក្នុងការកំណត់ នូវអាទិភាពនៃគម្រោងដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុសម្រាប់ការកៀរគរដៃគូគាំទ្រ។ ការ ចាត់ថ្នាក់ភាពងាយរងគ្រោះនៃគម្រោងនីមួយៗធ្វើឡើងដោយផ្អែកលើសំណួរ និងកម្រិតដូចខាងក្រោមៈ

- តើគម្រោងដែលស្នើអាចជួបប្រទះព្រឹត្តិការណ៍គ្រោះមហន្តរាយញឹកញាប់ប៉ុនណា ?
  - មិនដែលជួបប្រទះ
  - កម្រនឹងជួបប្រទះ (តិចជាង០៥ឆ្នាំម្តង)
  - ជាញឹកញាប់ (យ៉ាងហោចណាស់២ទៅ៥ឆ្នាំម្តង)
  - តែងតែជួបប្រទះ (យ៉ាងហោចណាស់១ឆ្នាំម្តង)
- តើរំពឹងទុកថា អាចនឹងមានការខូចខាតអ្វីខ្លះ ? (ជាការខូចខាតលើហេដ្ឋារចនាសម្ព័ន្ធ...)
  - មិនមាន
  - ខូចខាតតិចតួច
  - ខូចខាតទ្រង់ទាយ
  - ខូចខាតទាំងស្រុង

លទ្ធផលនៃការវិភាគនេះត្រូវយកមកផ្ទៀងផ្ទាត់នៅក្នុងតារាងដូចខាងក្រោម ៖

# តារាងការធ្វើចំណាត់ថ្នាក់ភាពងាយរងគ្រោះនៃគម្រោងបន្សាំការប្រែប្រួលអាកាសធាតុ

| ល.រ | ឈ្មោះគម្រោង | ប្រភេទ | ទីតាំង | ទីតាំងនៅក្នុងតំបន់ហានិភ័យ | | ភាពញឹកញាប់នៃផលប៉ះពាល់ | | | | ការខូចខាត | | | | ប្រភេទនៃភាពងាយរងគ្រោះ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មាន | មិនមាន | មិនដែល | កម្រមាន | ញឹកញាប់ | ជាប្រចាំ | មិនមាន | ខូចខាត តិចតួច | ខូចខាតខ្លាំង | ខូចទាំងស្រុង | |
| | | | | | | x | | | | x | | | | មិនមានហានិភ័យ |
| | | | | | | | X | | | | x | | | មានហានិភ័យទាប |
| | | | | | | | | x | | | | x | | មានហានិភ័យមធ្យម |
| | | | | | | | | | x | | | | x | មានហានិភ័យខ្ពស់ |
| | | | | | | | X | | | x | | | | មិនមានហានិភ័យ |
| | | | | | | | X | | | | | x | | មានហានិភ័យមធ្យម |
| | | | | | | | X | | | | | | x | មានហានិភ័យខ្ពស់ |
| | | | | | | | | x | | x | | | | មិនមានហានិភ័យ |
| | | | | | | | | x | | | x | | | មានហានិភ័យមធ្យម |
| | | | | | | | | x | | | | | x | មានហានិភ័យខ្ពស់ |
| | | | | | | | | | x | x | | | | មិនមានហានិភ័យ |
| | | | | | | | | | x | | x | | | មានហានិភ័យខ្ពស់ |
| | | | | | | | | | x | | | x | | មានហានិភ័យខ្ពស់ |

**ឧបសម្ព័ន្ធទី៦**

## ជំនួយស្មារតី
## នៅពេលរៀបចំសរសេរស្ថានភាពទូទៅ

នៅពេលសរសេរពីស្ថានភាពទូទៅ សក្តានុពល និងបញ្ហាប្រឈមរបស់មូលដ្ឋាន គ.ផ.ថ ត្រូវអនុវត្តតាមលំដាប់លំដោយដូចខាងក្រោម ៖

### រៀបចំតារាងទិន្នន័យ

តួលេខដែលយកមកបំពេញក្នុងតារាងសង្ខេបទិន្នន័យ ត្រូវស្រង់ចេញពីសៀវភៅទិន្នន័យភូមិ ឃុំ សង្កាត់ និងឯកសារព័ត៌មានស្ថានភាពមូលដ្ឋាន ដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយគេ។ តួលេខមួយចំនួនដូចជា ផ្ទៃដី ចំនួនឃុំ ចំនួនភូមិ គឺ គ.ផ.ថ ត្រូវបំពេញដោយខ្លួនឯង។ ក្រុមការងារអាចបន្ថែមព័ត៌មានផ្សេងទៀត ដែលខ្លួនយល់ថាមានសារៈសំខាន់ដល់ការរំលេចគុណភាពកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ដូចជា សូចនាករនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គោលដៅ និងចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តែមិនគួរបន្ថែមច្រើនពេកនាំឱ្យព័ត៌មានទាំងនោះប្រែទៅជាមិនសំខាន់ទៅវិញ។

ចំពោះឆ្នាំដំបូងនៃអាណត្តិក្រុមប្រឹក្សា ទិន្នន័យត្រូវយកទិន្នន័យឆ្នាំចាស់(ឆ្នាំកន្លងទៅ)ហើយទិន្នន័យនេះត្រូវបានធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ដោយបន្ថែមកូឡោនតាមឆ្នាំនីមួយៗនៃការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល។

### ការសរសេរពីស្ថានភាពសេដ្ឋកិច្ច

ក្នុងចំណុចនេះ គ.ផ.ថ ត្រូវធ្វើការកំណត់ និងសរសេរតាមបែបវិភាគអំពីសកម្មភាពសេដ្ឋកិច្ចចម្បងៗ និងបន្ទាប់បន្សំមួយចំនួន ដែលមានក្នុងមូលដ្ឋានដោយផ្អែកលើលទ្ធផលវិភាគផ្នែកសេដ្ឋកិច្ច។

សកម្មភាពសេដ្ឋកិច្ចចម្បង គឺសំដៅលើសកម្មភាពដែលប្រជាពលរដ្ឋភាគច្រើនអនុវត្ត ដើម្បីយកផលមកធ្វើជាកម្លាំងស្នូលក្នុងការទ្រទ្រង់ជីវភាពប្រចាំថ្ងៃ។ ចំណែកឯសកម្មភាពសេដ្ឋកិច្ចបន្ទាប់បន្សំ គឺសំដៅលើសកម្មភាពដែលប្រជាពលរដ្ឋមួយចំនួនអនុវត្តដើម្បីរកកម្រៃបន្ថែមសម្រាប់ការទ្រទ្រង់ជីវភាព (*ទោះបីជាបរិមាណចំណូលពីសកម្មភាពសេដ្ឋកិច្ចបន្ទាប់បន្សំអាចច្រើនជាងចំណូលពីសកម្មភាពសេដ្ឋកិច្ចចម្បងក៏ដោយ ក៏នៅតែចាត់ ទុកថាជាសកម្មភាពសេដ្ឋកិច្ចបន្ទាប់បន្សំ*)។

**ឧទាហរណ៍ ៖** ក្នុងឃុំដែលមានប្រជាពលរដ្ឋភាគច្រើនប្រកបរបរជាអាជីវករលក់ដូរ ដូច្នេះសកម្មភាពសេដ្ឋកិច្ចចម្បងគឺអាជីវកម្ម ទោះបីជាចំណូលពីការលក់ដូររបស់ប្រជាពលរដ្ឋម្នាក់ៗ អាចមានកម្រិតទាបជាងចំណូលពីសកម្មភាពផ្សេងក៏ដោយ។ ក្រុមការងារត្រូវវិភាគស្ថានភាពអាជីវកម្មជាក់ស្តែងក្នុងស្រុកដោយពិនិត្យពីកត្តាអ្វីខ្លះដែលបានជំរុញ និងអ្វីខ្លះជាឧបសគ្គដល់ការឈានឡើងទាំងចំពោះមុខ និងយូរអង្វែងរបស់វិស័យនេះក្នុងស្រុក ហើយដែលកំពុងជះឥទ្ធិពលលើកម្រិតជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ទន្ទឹមនេះ ត្រូវបរិយាយពីអ្វីខ្លះដែលនាំឱ្យមានការផ្លាស់ប្តូរក្នុងមុខរបរជំនួញ (ឧទាហរណ៍ ៖ កត្តាសេដ្ឋកិច្ចប្រែប្រួល) ហើយអ្វីខ្លះដែលស្រុកត្រូវធ្វើការព្យាយាមទប់ស្កាត់ ឬគ្រប់គ្រង ការផ្លាស់ប្តូរទាំងនេះ ដើម្បីធានានិរន្តរភាព និងភាពរីកចម្រើនក្នុងវិស័យនេះ។ ចំពោះឃុំដែលមានប្រជាពលរដ្ឋភាគច្រើនប្រកបរបរធ្វើស្រែ សកម្មភាពសេដ្ឋកិច្ចចម្បងសម្រាប់ឃុំនោះ គឺកសិកម្ម ទោះបីជាចំណូលបានមកពីការធ្វើស្រែរបស់ប្រជាកសិករម្នាក់ៗអាចតិចជាងចំណូលពីសកម្មភាពផ្សេងក៏ដោយ។

## សកម្មភាពចម្បង

ក្នុងផ្នែកសេដ្ឋកិច្ច រួមមាន ៖

- **អាជីវកម្ម ៖** មុខរបរសំខាន់ៗក្នុងវិស័យអាជីវកម្មរួមមាន មុខរបរជំនួញ ប្រភេទសិប្បកម្មនានា ជាងជួសជុល។ល។ ក្នុងស្ថានភាពអាជីវកម្ម ត្រូវសរសេររៀបរាប់ពីសក្តានុពលសំខាន់ៗរបស់មូលដ្ឋាន និងបញ្ហាប្រឈមនានាដែលមូលដ្ឋានកំពុងជួបប្រទះ។
- **កសិកម្ម** ៖ សកម្មភាពសំខាន់ៗក្នុងវិស័យកសិកម្មរួមមាន ការដាំដុះស្រូវ ដំណាំកសិ ឧស្សាហកម្ម និងដំណាំរួមផ្សំ ការចិញ្ចឹមសត្វនិងត្រី ការប្រើប្រាស់ជីធ្លី និងប្រព័ន្ធធារាសាស្រ្តដែលជួយគាំទ្រដល់ការងារកសិកម្ម។ ក្នុងស្ថានភាពកសិកម្ម ត្រូវសរសេររៀបរាប់អំពីសក្តានុពលសំខាន់ៗរបស់មូលដ្ឋាននិងបញ្ហាប្រឈមនានាកំពុងជួបប្រទះនៅក្នុងមូលដ្ឋាន។
- **ឧស្សាហកម្ម ៖** សកម្មភាពសំខាន់ៗក្នុងវិស័យឧស្សហកម្មរួមមាន សកម្មភាពសិប្បកម្ម រោងចក្រ និងការងារសំណង់ជាដើម។ ដូច្នេះ ត្រូវសរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗដែលពាក់ព័ន្ធនឹងវិស័យនេះ។
- **គមនាគមន៍ ៖** សរសេររៀបរាប់អំពីសក្តានុពលនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវគោក និងផ្លូវទឹកដែលឃុំមាន និងបញ្ហាប្រឈមសំខាន់ៗដែលមូលដ្ឋានកំពុងជួបប្រទះ។
- **សេវាកម្ម ៖** សរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមនៃសេវាកម្មនានាពាក់ព័ន្ធនឹងសាធារណការ ទឹកស្អាត អគ្គិសនី ទីផ្សារ ទេសចរណ៍ ។ល។
- **ការវិនិយោគ ៖** ចំណុចនេះត្រូវសរសេររៀបរាប់អំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងវិស័យឯកជនជាមួយស្រុកដើម្បីរៀបចំគម្រោងអភិវឌ្ឍន៍នានាក្នុងឃុំ ដូចជាការអភិវឌ្ឍផ្សារ ចំណតរថយន្ត ផ្លូវ ស្ពាន និងគម្រោងអភិវឌ្ឍន៍ផ្សេងទៀត។ ដូច្នេះត្រូវសរសេររៀបរាប់ពីសក្តានុពល និងបញ្ហាប្រឈមចម្បងៗដែលពាក់ព័ន្ធនឹងការវិនិយោគនេះ។
- **ការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ៖** ត្រូវសរសេររៀបរាប់អំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយពាណិជ្ជករ ឬក្រុមហ៊ុនក្នុងស្រុក ក្រៅស្រុក ឬកិច្ចសហប្រតិបត្តិការ ឬការចងសម្ព័ន្ធមេត្រីជាមួយអាជ្ញាធររដ្ឋបាលនានាដើម្បីអភិវឌ្ឍន៍មូលដ្ឋានដូចជា ការបង្កើតតំបន់អភិវឌ្ឍន៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការការពារទឹកជំនន់ និងការអភិវឌ្ឍទីផ្សារជាដើម។ ដូច្នេះត្រូវសរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗ ដែលពាក់ព័ន្ធនឹងការងារទាំងនេះ។

ក្រៅពីចំណុចសំខាន់ដែលបានរៀបរាប់ខាងលើ ក្រុមការងារអាចបន្ថែមនូវចំណុចផ្សេងទៀត ដែលយល់ថាចាំបាច់ និងគួរបញ្ចូលក្នុងកម្មវិធីវិនិយោគ។ ការសរសេររៀបរាប់ចំណុចបន្ថែមនេះគឺដូចគ្នានឹងចំណុចនានាខាងលើដោយផ្តោតលើសក្តានុពល និងបញ្ហាប្រឈមនានា។

## ការសរសេរពីស្ថានភាពសង្គមកិច្ច

ស្ថានភាពសង្គមកិច្ចគឺជាផ្នែកមួយដែលត្រូវធ្វើការសិក្សាពីលក្ខណៈប្រជាសាស្រ្ត សេវាសាធារណៈផ្នែកសង្គម និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋ ដូចជា៖ ស្ថានភាពអប់រំ សុខុមាលភាព យេនឌ័រ ភាពក្រីក្រ អំពើហិង្សាការជួញដូរស្ត្រីនិងកុមារ ការលើកកម្ពស់សិទ្ធិមនុស្ស និងស្ថានភាពសាសនាជាដើម។ ពេលសរសេរអំពីស្ថានភាពសង្គមកិច្ច ត្រូវសរសេរតាមបែបវិភាគដោយផ្អែកលើលទ្ធផលនៃការវិភាគសង្គមកិច្ច និងត្រូវផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

- **អប់រំ ៖** សរសេរពីការសម្រេចបានរបស់វិស័យអប់រំ ដូចជា ការសិក្សារបស់កុមារ ស្តង់ដារអប់រំ (ការចូលរៀនរបស់កុមារនៅថ្នាក់មត្តេយ្យ បឋមសិក្សា អនុវិទ្យាល័យ ការបោះបង់ចោលការសិក្សា ការរៀនត្រួតថ្នាក់ ពិសេសក្មេងស្រី ការងារអក្ខរកម្ម...)។
- **សុខាភិបាល ៖** សរសេរពីស្ថានភាពសុខភាពរបស់ប្រជាជន ពិសេសស្ត្រីនិងកុមារ កម្រិតនៃការទទួលបានសេវាសុខភាព អត្រាមរណភាពមាតានិងទារក គ្រោះថ្នាក់កើតពីជំងឺផ្សេងៗ និងបញ្ហានានាដែលពាក់ព័ន្ធនឹងសុខភាពមាតានិងកុមារ ទឹកស្អាត អនាម័យ បញ្ហាយុវវ័យ សុខភាពបន្តពូជ ។ល។
- **យេនឌ័រ ៖** គួរសរសេរពីការទទួលយកសេវា ការចូលរួមចំណែករបស់ស្ត្រីក្នុងការសម្រេចចិត្តនានា និងសកម្មភាពសង្គម និងការលំបាកដែលស្ត្រីកំពុងជួបប្រទះ (បុរសពុំបានជួប) ឬកត្តាទាំងឡាយក្នុងសង្គម ដែលនាំឱ្យស្ត្រីជួបការលំបាកញឹកញាប់ជាងបុរស។
- **ភាពក្រីក្រ ៖** សរសេរពីកម្រិតក្រីក្ររបស់ប្រជាជនដោយបង្ហាញពីមូលហេតុចម្បងៗដែលនាំឱ្យមានគ្រួសារមួយចំនួនធ្លាក់ខ្លួនក្រ មូលហេតុដែលគ្រួសារក្រីក្រមិនអាចកែលម្អជីវភាពរបស់ពួកគេបាន និងមូលហេតុដែលនាំឲ្យគ្រួសារក្រីក្របានកែលម្អជីវភាពខ្លួន។
- **សាសនា ៖** រៀបរាប់ពីប្រភេទសាសនា និងចំនួនភាគរយប្រជាពលរដ្ឋ ដែលកាន់សាសនានីមួយៗ។
- **អន្តោប្រវេសន៍ និងការផ្លាស់ទីលំនៅ ៖** ត្រូវសរសេររៀបរាប់ពីស្ថានភាពនៃការផ្លាស់ទីលំនៅរបស់ប្រជាពលរដ្ឋពីតំបន់ផ្សេងៗចូលមកមូលដ្ឋានខ្លួនដើម្បីប្រកបមុខរបរនានា ដូចជា ៖ ប្រកបមុខរបរជាកម្មកររត់ម៉ូតូឌុប កម្មកររោងចក្រ និងជនបរទេសដែលចូលមកជាអ្នកទេសចរ ឬមកប្រកបមុខរបរ។ ចំណុចនេះ ត្រូវសរសេររៀបរាប់ពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗ ដែលពាក់ព័ន្ធនឹងស្ថានភាពទាំងនេះ។

ក្រៅពីស្ថានភាពសំខាន់ៗខាងលើ ក្រុមការងារអាចធ្វើការរៀបរាប់បន្ថែមពីស្ថានភាពផ្សេងទៀតដែលពាក់ព័ន្ធនឹងស្ថានភាពសង្គមកិច្ច តាមស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាន ដូចជាការលើកកម្ពស់សិទ្ធិកុមារ និងប្រជាពលរដ្ឋទូទៅ ការទប់ស្កាត់សកម្មភាពជួញដូរស្ត្រីនិងកុមារ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការជួយជនចាស់ជរាគ្មានទីពឹង និវត្តជន កុមារកំព្រា ជនអនាថា។ល។

## ការសរសេរស្ថានភាពធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

ផ្នែកនេះត្រូវសរសេររៀបរាប់ពីអ្វីខ្លះដែលជាភាពខ្លាំង(សក្តានុពល)និងផលប្រយោជន៍ ដែលមានដូចជាដីធ្លីនិងធនធានធម្មជាតិ និងអ្វីខ្លះដែលជាបញ្ហាប្រឈម ឬឧបសគ្គដែលកំពុងគំរាមកំហែងដល់ដីធ្លី ធនធានធម្មជាតិនិងបរិស្ថាន។ ទន្ទឹមនេះ ត្រូវសរសេររៀបរាប់ពីគ្រោះថ្នាក់ ការបាត់បង់ខូចខាត ការបំផ្លិចបំផ្លាញ ការប្រែប្រួល និងផលប៉ះពាល់ជាអវិជ្ជមានពីបាតុភូតទាំងឡាយកើតមានឡើង ដែលបង្កដោយមនុស្ស ឬដោយធម្មជាតិ។

ការសរសេរផ្នែកនេះត្រូវផ្អែកលើលទ្ធផលនៃការវិភាគការប្រើប្រាស់ដីធ្លី ការវិភាគធនធានធម្មជាតិ ការវិភាគបរិស្ថាន និងការវិភាគគ្រោះមហន្តរាយ ដោយផ្តោតលើ៖

- **ការប្រើប្រាស់ដីធ្លី ៖** ត្រូវរៀបរាប់ពីបញ្ហាប្រឈមសំខាន់ៗ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ដីលំនៅដ្ឋាន ដីធ្វើស្រែ ដីចំការ ដីសម្រាប់ការវិនិយោគ ដីសម្បទាន តំបន់អភិរក្ស។ល។ ចំពោះការប្រើប្រាស់ដីសម្រាប់លំនៅដ្ឋាន ត្រូវរៀបរាប់ពីសក្តានុពលនិងបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការកំណត់ប្រភេទលំនៅដ្ឋាន ការផ្លាស់ប្តូរទីតាំង ការរៀបចំនិងគ្រប់គ្រងសំណង់អានាធិបតេយ្យ និងការរៀបចំប្លង់លំនៅដ្ឋានជាដើម។ល។

- **ធនធានធម្មជាតិ ៖** បរិយាយពីធនធានធម្មជាតិសំខាន់ៗ ដែលមាន ដូចជា ៖ ដីធ្លី ព្រៃឈើ សត្វព្រៃ ធនធានជលផល បឹង អូរ ស្ទឹង រ៉ែ...។ល។ ដែលប្រជាជនពឹងផ្អែកលើធនធានទាំងនេះសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់។ ដូច្នេះ ត្រូវសរសេរពីកម្រិតនៃការប្រើប្រាស់ធនធានទាំងនេះ និងបញ្ហាប្រឈមចម្បងៗដែលកំពុងជួបប្រទះពាក់ព័ន្ធនឹងការប្រើប្រាស់នេះ។
- **បរិស្ថាន ៖** ត្រូវរៀបរាប់ពីសក្ដានុពលពាក់ព័ន្ធនឹងបរិស្ថាន ដូចជាកន្លែងហាត់ប្រាណ និងសួនឧទ្យានសាធារណៈ ទីលានចាក់សំរាម និងបញ្ហានានា ដែលគំរាមកំហែងលើបរិស្ថាន ដូចជាការបំពុលបរិយាកាស កាកសំណល់រឹង និងរាវ។ល។
- **គ្រោះមហន្តរាយចម្បងៗ ៖** រៀបរាប់ពីស្ថានភាពនៃការបំផ្លិចបំផ្លាញដោយសារខ្យល់ព្យុះ ខ្យល់កន្ត្រាក់ ភ្លើងឆេះផ្ទះ គ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌមិនទាន់ផ្ទុះ គ្រោះទឹកជំនន់។ល។
- **ការប្រែប្រួលអាកាសធាតុ ៖** រៀបរាប់ពីទឹកជំនន់ ភាពរាំងស្ងួត សីតុណ្ហភាពឡើងខ្ពស់ កម្រិតទឹកភ្លៀងមិនទៀងទាត់។

## ការសរសេរពីស្ថានភាពរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ផ្នែកនេះត្រូវសរសេររៀបរាប់ដោយសង្ខេបពីចំណុចសំខាន់ៗ ដូចជា អភិបាលកិច្ច ការគ្រប់គ្រងដែនដី ស្ថិតិប្រជាជន កិច្ចការសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដោយផ្អែកលើលទ្ធផលនៃការវិភាគស្ថានភាពរដ្ឋបាលសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។ ទិន្នន័យនិងព័ត៌មានមួយចំនួន ដែលត្រូវរៀបរាប់ក្នុងផ្នែកនេះមានបង្ហាញក្នុងតារាងផ្ទៃដី ភូមិសាស្ត្រមូលដ្ឋាន (ចំនួនភូមិ) និងស្ថិតិប្រជាជន។

- **អភិបាលកិច្ច ៖** រៀបរាប់ពីភាពខ្លាំង និងបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងអភិបាលកិច្ច។
- **គ្រប់គ្រងដែនដី៖** រៀបរាប់ពីភាពខ្លាំង និងបញ្ហាប្រឈមពាក់ព័ន្ធនឹងការរៀបចំ និងគ្រប់គ្រងដែនដីរដ្ឋបាល ដូចជា៖ ការកំណត់ព្រំប្រទល់ដែនដីភូមិសាស្ត្ររដ្ឋបាល និងតំបន់សំខាន់ៗក្នុងមូលដ្ឋាន ការបង្កើតក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិថ្មី ការរៀបចំប្លង់គោលជាដើម។
- **ការគ្រប់គ្រងស្ថិតិ៖** រៀបរាប់ពីបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការចុះបញ្ជី និងការងារអត្រានុកូលដ្ឋាន។
- **ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ៖** រៀបរាប់ពីភាពខ្លាំង និងបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រង ការរក្សាសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ នៅតំបន់ទីប្រជុំជនសំខាន់ៗ។

**ចំពោះឃុំ ជាប់ព្រំដែនគួរបញ្ចូលការងារព្រំដែន ៖** ភាពងាយស្រួល និងការលំបាកក្នុងការរៀបចំ និងគ្រប់គ្រងប្រកព្រំដែន និងកិច្ចសហការជាមួយប្រទេសជិតខាង។